# ព្រះវិញ្ញាណបរិសុទ្ធ

លោក ខេវីន ឌីយ៉ាំង Kevin DeYoung

កូនសៀវភៅដៃគូក្នុងដំណឹងល្អ
http://www.dkdl.org

**The Plan**
**Copyright © 2012 by The Gospel Coalition**

**Published by Crossway**
**a publishing ministry of Good News Publishers**
**Wheaton, Illinois 60187, U.S.A.**

**This edition published by arrangement with Crossway.**
**All rights reserved.**

**This project was accomplished in partnership with The Gospel Coalition International Outreach.**

# មាតិកា

ព្រះវិញ្ញាណបរិសុទ្ធគង់ពេញក្នុងព្រះគម្ពីរ ៥

តើព្រះវិញ្ញាណបរិសុទ្ធគឺជានរណា? ៩

ការងាររបស់ព្រះវិញ្ញាណបរិសុទ្ធ ១១

រឿងរីករាយមួយអំពីបុណ្យណូអែលគឺជាការទទួលបានអំណោយ។ អ្នកខ្លះទទួលបានតិច អ្នកខ្លះទទួលបានយ៉ាងច្រើនពេក។ កាលពីឆ្នាំទៅខ្ញុំបានទទួលសៀវភៅ សំលៀកបំពាក់ Nintendo Wii (សម្រាប់ក្មេង) និងរូបតុក្កតាចន កាលវិន មួយ។ព្រះមិនដូចជារដ្ឋាភិបាលដែលឆ្លើយតបចំពោះស្ថានភាពដែលមិនបានមើលឃើញជាមុន និងផ្លាស់ប្តូរនយោបាយពីព្រោះមានព្រឹត្តិការណ៍កើតឡើងដែលគេមិនបានដឹងជាមុននោះទេ។ ទ្រង់មិនដូចជាអ្នកវិទ្យាសាស្ត្រដែលពិសោធន៍មើលការងារអ្វី ឬសហគ្រិនពាណិជ្ជកម្មដែលជោគជ័យដោយសារការស្វែងរកគំនិតថ្មីៗឆ្លើយតបចំពោះសេចក្តីត្រូវការដែលលេចឡើងផ្សេងៗនោះទេ។

សូមគិតអំពីអំណោយជាទីពេញចិត្តរបស់អ្នក មិនគ្រាន់តែពីបុណ្យណូអែលទេ ប៉ុន្តែអំណោយដែលល្អបំផុតដែលអ្នកធ្លាប់ទទួលបាន។ ចិញ្ចៀនភ្ជាប់ពាក្យត្រូវតែជាអំណោយល្អណាស់។ ប៉ុន្តែយ៉ាងម៉េចដែរបើសិនខ្ញុំបានប្រាប់អ្នកអំពីអំណោយមួយដែលផ្តល់សេចក្តីសន្យាល្អជាង ជាប់នៅបានយូរជាងអាពាហ៍ពិពាហ៍ទៅទៀតនោះ? ប្រហែលប្រាក់ជាអំណោយជាទីពេញចិត្តរបស់អ្នក។ អ្នកអាចមានឥទ្ធិពលខ្លាំងនិងអាចធ្វើការរីករាយជាច្រើនដោយសារអ្នក

មានប្រាក់។ ប៉ុន្តែយ៉ាងម៉េចដែរបើសិនជាខ្ញុំបានប្រាប់អ្នកអំពីអំណោយមួយដែលផ្ដល់នូវអំណាចផ្លាស់ប្រែជីវិតជាង និងឥទ្ធិពលផ្លាស់ប្រែលោកិយជាងទ្រព្យសម្បត្តិទៅទៀតនោះ?ប្រហែលជាអំណោយដ៏មានតំលៃបំផុតរបស់អ្នកគឺជារូបថតដែលមិត្តភ័កនិងគ្រួសារបានឲ្យ។ យ៉ាងម៉េចដែរបើសិនជាខ្ញុំបានប្រាប់អ្នកអំពីអំណោយមួយដែលពិសេសជាងរូបថតរបស់អ្នកជាទីស្រលាញ់របស់អ្នក គឺវាផ្ដល់ឲ្យអ្នកនូវវត្តមានរបស់ទ្រង់ជាមួយអ្នកគ្រប់ពេលវេលានោះ?

នេះគឺជាអំណោយដ៏អស្ចារ្យមួយ ជាអំណោយនៃសេចក្ដីសន្យាមួយ ជាអំណោយនៃអំណាចព្រះចេស្ដាមួយ និងជាអំណោយនៃព្រះវត្តមានមួយ ហើយមនុស្សរាប់លានអ្នកបានទទួលអំណោយនេះ។ អំណោយនេះគឺជាព្រះវិញ្ញាណបរិសុទ្ធ។ គ្មានទ្រព្យសម្បត្តិណាដែលមានតំលៃ មានប្រយោជន៍ មានឫទ្ធិ មានឫទ្ធានុភាព ខ្លាំង និងមានសេចក្ដីស្រលាញ់ដូចជាព្រះវិញ្ញាណដែលគង់ក្នុងអស់អ្នកដែលជារបស់ព្រះតាមរយៈព្រះគ្រីស្ទនោះទេ (១កូរិនថូស ៣:១៦)។

## ព្រះវិញ្ញាណបរិសុទ្ធគង់ពេញក្នុងព្រះគម្ពីរ

ពាក្យ “វិញ្ញាណ” ជាភាសាហេព្រើរគឺ ruach និងជាភាសាក្រិកគឺ pneuma។ ruach ត្រូវបានប្រើចំនួនប្រហែលកៅសិបដងសំដៅលើព្រះវិញ្ញាណបរិសុទ្ធនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ pneuma ត្រូវបានប្រើលើសជាង២៥០ដងសំដៅលើព្រះវិញ្ញាណនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ ពាក្យទាំងពីរនេះអាចសំដៅលើខ្យល់និងការដកដង្ហើម។ គំនិតទូទៅគឺដូចគ្នា ruach និង pneuma បញ្ជាក់អំពីឫទ្ធានុភាព ចលនា ជីវិតនិងសកម្មភាព។ ព្រះវិញ្ញាណបរិសុទ្ធគឺជា

ព្រះវិញ្ញាណដែលត្រូវបានញែកចេញនិងជារបស់ព្រះ។ ទ្រង់គឺជាអំណាចនិងវត្តមានរបស់ព្រះក្នុងចំណោមរាស្ត្ររបស់ទ្រង់។[១]

ថ្វីបើយើង «មើលឃើញ» ព្រះវិញ្ញាណបរិសុទ្ធជាងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ក៏ទ្រង់បានកំពុងធ្វើការនៅក្នុងព្រះគម្ពីរសញ្ញាចាស់ផងដែរ។ ទ្រង់បានមានវត្តមាននៅឯការបង្កបង្កើត អោយលើផ្ទៃទឹក ដើម្បីបញ្ចប់អ្វីដែលព្រះវរបិតាបានមាន គោលបំណងនិង គម្រោងផែនការ (លោកុប្បត្តិ ១:២)។ ព្រះវិញ្ញាណបរិសុទ្ធបានកំពុងធ្វើនៅក្នុងការរំដោះចេញពីការគ្រប់គ្រងរបស់ស្រុកអេស៊ីព្ទ (អេសាយ ៦៤:៧-១៤)។ ទ្រង់ប្រទានអំណោយទានដល់រាស្ត្ររបស់ព្រះសម្រាប់ការបម្រើ ប្រទានអំណោយទានដល់បេសាលាល និងអូហូលីអាប់មិនត្រឹមតែខាងការងារចំឡាក់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់បានប្រទានអំណាចនៃព្រះវិញ្ញាណដើម្បីសាងសង់គំរូនិងលំនាំស្ថានសួគ៌នៅលើផែនដីទៀតផង (និក្ខមនំ ៣៥:៣០-៣៥)។ ជារឿយៗយើងឃើញនៅក្នុងព្រះគម្ពីរសញ្ញាចាស់ពីរបៀបដែលព្រះវិញ្ញាណ បានសណ្ឋិតលើបុគ្គលដូចជា បាឡាម,គេឌាន, យ៉េបថា, សាំសុន និងអ័សាភសម្រាប់ការនិយាយនិង សកម្មភាពពិសេស (ជនគណនា ២៤:២ ចៅហ្វាយ ៦:៣៤, ១១:២៩, ១៣:២៥, ១៤:៦, ១៩, ១៥:១៤, ២របាក្សត្រ ១៥:១)។ ព្រះវិញ្ញាណអាចយាងមកសណ្ឋិតលើមនុស្សសម្រាប់រយៈពេលមួយបន្ទាប់មកក៏ចាកចេញទៅ ដូចជាសូល (១សាំយ៉ូអែល ១៦:១៤ និងដាវីឌក៏បានភ័យខ្លាចព្រះវិញ្ញាណបរិសុទ្ធនឹងចាកចេញទៅដែរ (ទំនុកដំកើង ៥១:១១)។

សកម្មភាពរបស់ព្រះវិញ្ញាណនៅក្នុងព្រះគម្ពីរសញ្ញាចាស់គឺមានអំណាច

ព្រះចេស្តា ប៉ុន្តែមិនទាន់ពេញលេញនៅឡើយទេ។ នោះយើងនឹងមិនមានការភ្ញាក់ផ្អើលឡើយថា ព្រះគម្ពីរសញ្ញាចាស់ទន្ទឹងរង់ចាំសម័យកាលនៃព្រះវិញ្ញាណដែលនឹងមកដល់នោះទេ។ មានទំនាយបីដែលទាយអំពីសិរីល្អនៃថ្ងៃថ្មីនោះ។ យ៉ូអែល ២:២៨-៣២ទន្ទឹងរង់ចាំព្រះវិញ្ញាណយាងមកសណ្ឋិតលើរាស្ត្ររបស់ព្រះទាំងអស់។ អេសេគាល ៣៦:២២-៣៧:១៤ រង់ចាំថ្ងៃដែលព្រះវិញ្ញាណនឹងគង់នៅក្នុងរាស្ត្ររបស់ព្រះដោយផ្ទាល់និងជាដរាប។ អេសាយ ១១:១-៥ សន្យាអំពីលំពង់មួយពីគល់របស់អ៊ីសាយដែលត្រូវបានចាក់ប្រេងតាំងដោយព្រះវិញ្ញាណនឹងនាំថ្ងៃនៃសេចក្តីសង្គ្រោះមកសម្រាប់អ៊ីស្រាអែល។ ព្រះវិញ្ញាណដែលគង់សណ្ឋិតលើរាស្ត្រទាំងអស់របស់ព្រះ ព្រះវិញ្ញាណដែលគង់នៅក្នុងយើង និងព្រះអង្គសង្គ្រោះដែលមានព្រះវិញ្ញាណនៃព្រះសណ្ឋិតនៅលើនេះគឺជាសម័យកាលនៃព្រះវិញ្ញាណដែលព្រះគម្ពីរសញ្ញាចាស់បានទាយទុកជាមុន។ ការចាក់បង្ហូរព្រះវិញ្ញាណនេះកើតឡើងនៅក្រោមសម្ព័ន្ធមេត្រីថ្មី (២កូរិនថូស ៣:១-១១)។ ព្រះអង្គបានចាក់បង្ហូរវិញ្ញាណរបស់ព្រះលើមនុស្សទាំងអស់ (កិច្ចការ ២:១៤-២១) ព្រះវិញ្ញាណបរិសុទ្ធគង់ក្នុងអស់អ្នកជឿ (រ៉ូម ៨:៩) ហើយប្រទានអំណាចនិងថ្វាយសិរីល្អដល់ព្រះមែស្ស៊ីដែលព្រះវិញ្ញាណចាក់ប្រេងតាំងនៅក្នុងព័ន្ធកិច្ចនិងការងារប្រោសលោះរបស់ទ្រង់នៅលើផែនដី។

ព្រះគម្ពីរសញ្ញាថ្មីសង្កត់ធ្ងន់លើចំនុចចុងក្រោយនោះ(ព្រះវិញ្ញាណបរិសុទ្ធប្រទានអំណាចនិងថ្វាយសិរីល្អដល់ព្រះមែស្ស៊ី)ច្រើនជាងដែលយើងបានដឹង។ ព្រះវិញ្ញាណបានប្រទានអំណាចដល់ព្រះរាជបុត្រាគ្រប់ក្នុងកាលនៃព័ន្ធកិច្ចរបស់ទ្រង់។ ព្រះវិញ្ញាណបរិសុទ្ធបានប្រទានអំណាចព្រះចេស្តាដល់នាងម៉ារាឲ្យ

មានផ្ទៃពោះ (ម៉ាថាយ ១:១៨, ២០លូកា ១:៣៥)។ ព្រះវិញ្ញាណបរិសុទ្ធបាន សណ្ឋិតលើស៊ីម្មាននៅពេលគាត់បានប្រកាសអំពីព្រះយេស៊ូវនៅក្នុងព្រះវិហារ (លូកា ២:២៥)។ ព្រះវិញ្ញាណបានសណ្ឋិតលើព្រះយេស៊ូវនៅពេលទ្រង់ទទួល បុណ្យជ្រមុជទឹក (ម៉ាថាយ ៣:១៦)។ លោកលូកាបានសរសេរថា បន្ទាប់មក ព្រះយេស៊ូវបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយព្រះវិញ្ញាណបាននាំ ទ្រង់ទៅក្នុងទីរហោស្ថានឲ្យត្រូវអារក្សល្បួង (ម៉ាថាយ ៤:១, លូកា ៤:១)។ បន្ទាប់ពីការត្រូវល្បួង នោះព្រះយេស៊ូវបាន យាងត្រឡប់ទៅស្រុកកាលីឡេ វិញដោយអំណាចនៃព្រះវិញ្ញាណ (លូកា ៤:១៤) ហើយបានប្រកាសនៅក្នុង សាលាប្រជុំថា ព្រះវិញ្ញាណនៃព្រះអម្ចាស់បានគង់សណ្ឋិតលើទ្រង់ឲ្យប្រកាស ដំណឹងល្អដល់អ្នកក្រីក្រ (៤:១៨)។

ព្រះយេស៊ូវបានដេញអារក្សដោយព្រះវិញ្ញាណនៃព្រះ (ម៉ាថាយ ១២:២៨)។ ហេព្រើរ ៩:១៤ និយាយថា គឺតាមរយៈព្រះវិញ្ញាណដ៏គង់នៅអស់កល្បដែល ព្រះគ្រីស្ទបានប្រទានអង្គទ្រង់ជាយញ្ញបូជាចំពោះព្រះ។ ក្នុងរ៉ូម ១:៤ លោក ប៉ុលសរសេរថា «ខាងឯព្រះវិញ្ញាណនៃសេចក្តីបរិសុទ្ធនោះបានសំដែងមក ច្បាស់ថាទ្រង់ជាព្រះរាជបុត្រារបស់ព្រះពិតទាំងមានព្រះចេស្តាផងដោយទ្រង់ បានរស់ពីស្លាប់ឡើងវិញគឺជាព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់»។ចាប់តាំងពី ការចាប់ទំផ្ទៃដល់ការប្រសូត, ព័ន្ធកិច្ច, ការសុគត និងការរស់ពីសុគតឡើង វិញ នោះព្រះវិញ្ញាណបានធ្វើការក្នុងយើងនិងតាមរយៈព្រះគ្រីស្ទ។

## តើព្រះវិញ្ញាណបរិសុទ្ធគឺជានរណា?

### *ព្រះអង្គ(ឬបុគ្គល)មួយដែលចេះទាក់ទងនិងមានអារម្មណ៍និងព្រះហឫទ័យ*

ព្រះវិញ្ញាណបរិសុទ្ធគឺជាបុគ្គលមួយ។ ទ្រង់ព្រួយព្រះទ័យ (អេភេសូរ ៤:៣០) ទូលអង្វរ (រ៉ូម ៨:២៦-២៧) ធ្វើបន្ទាល់ (យ៉ូហាន ១៦:១២-១៥) មានបន្ទូល (ម៉ាកុស ១៣:១១) បង្កើត (លោកុប្បត្តិ ១:២ លូកា ១:៣៥) មានគំនិត (រ៉ូម ៨:២៧) និងអាចត្រូវគេប្រមាថ (ម៉ាកុស ៣:២៨-២៩)។[២] (ការពិត យើងថាព្រះគម្ពីរ «ធ្វើបន្ទាល់» និង«និយាយ» ប៉ុន្តែគ្មានអ្នកណាថាព្រះគម្ពីរគឺជាមនុស្សនោះទេ។ តែក្នុងករណីបែបដូចនេះអត្ថបទនេះមានន័យថា ព្រះមានបន្ទូលនិងធ្វើបន្ទាល់តាមរយៈព្រះគម្ពីរ)។ នៅក្នុង យ៉ូហាន ជំពូក ១៤-១៦ ព្រះយេស៊ូវសន្យានឹងបញ្ជូន «ព្រះដ៏ជាជំនួយមួយអង្គទៀត» ជាព្រះវិញ្ញាណបរិសុទ្ធដែលជាអ្នកស្នងព័ន្ធកិច្ចលើផែនដីរបស់ព្រះយេស៊ូវនិងជាការជំនួសរបស់ទ្រង់។ អំណាចដែលមិនមែនជាបុគ្គល គឺមិនចេះទាក់ទងគ្នាហើយមិនមានព្រះហឫទ័យ នោះមិនស៊ីគ្នានឹងការពិពណ៌នារបស់ទ្រង់អំពីព្រះវិញ្ញាណនិងអ្វីដែលព្រះវិញ្ញាណនឹងធ្វើ។

### *ព្រះ*

ព្រះវិញ្ញាណបរិសុទ្ធមិនគ្រាន់តែជាបុគ្គលមួយប៉ុណ្ណោះទេ តែទ្រង់ក៏ជាអង្គបុគ្គលផងដែរ។ ទំនុកដំកើង១៣៩:៧ បង្ហាញអំពីការគង់នៅសព្វទីកន្លែងរបស់ទ្រង់។ ទ្រង់គឺជា «ព្រះវិញ្ញាណដ៏គង់នៅអស់កល្បជានិច្ច» (ហេព្រើរ៩:១៤)។[៣]

ការកុហកព្រះវិញ្ញាណបរិសុទ្ធគឺដូចគ្នាទៅនឹងការកុហកព្រះដែរ (កិច្ចការ ៥:៣-៤)។ លោកប៉ុលប្រើឃ្លា “ព្រះវិហារនៃព្រះ” ដូចគ្នានឹង “ព្រះវិហារនៃព្រះវិញ្ញាណបរិសុទ្ធ” (១កូរិនថូស ៣:១៦, ៦:១៩)។ ថ្វីបើព្រះវិញ្ញាណបរិសុទ្ធខុសពីព្រះវរបិតានិងព្រះរាជបុត្រា ក៏ទ្រង់មានខ្លឹមសារដូចព្រះវរបិតានិងព្រះរាជបុត្រាដែរ (សូមមើលម៉ាថាយ ២៨:១៩, ១កូរិនថូស ១២:៤-៦, ២កូរិនថូស ១:២១-២២, ១៣:១៤, ១ពេត្រុស ១:២)។ ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះ ប៉ុន្តែទ្រង់មិនមែនជាព្រះវរបិតាឬព្រះរាជបុត្រានោះទេ។ ទ្រង់គឺជាអង្គបុគ្គលផ្ទាល់របស់ទ្រង់។

## *ខុសពីព្រះវរបិតានិងព្រះរាជបុត្រា*

ថ្វីបើទ្រង់ខុសពីព្រះវរបិតានិងព្រះរាជបុត្រាក៏ដោយ ក៏ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះវិញ្ញាណនៃព្រះនិងជាព្រះវិញ្ញាណនៃព្រះគ្រីស្ទ (រ៉ូម ៨:៩)។ ការនិយាយថា “ព្រះវិញ្ញាណនៃព្រះគង់ក្នុងអ្នក” ឬ “ព្រះវិញ្ញាណនៃព្រះគ្រីស្ទគង់ក្នុងអ្នក” ឬ “ព្រះគ្រីស្ទគង់ក្នុងអ្នក” គឺជារបៀបនិយាយបីដូចគ្នាទេ (រ៉ូម ៨:១០)។[៤] ព្រះវរបិតាបញ្ជូនព្រះវិញ្ញាណ (យ៉ូហាន ១៤:២៦) ហើយព្រះរាជបុត្រាក៏បញ្ជូនព្រះវិញ្ញាណ (១៦:៧, ២០:២២)។[៥] លោកប៉ុលបានសរសេរថា អត្តសញ្ញាណរបស់ព្រះរាជបុត្រានិងព្រះវិញ្ញាណមានការពាក់ព័ន្ធគ្នា “ព្រះអម្ចាស់ដ៏ជាវិញ្ញាណ” (២កូរិនថូស ៣:១៧-១៨)។

នេះមិនមានន័យថា ព្រះរាជបុត្រានិងព្រះវិញ្ញាណគឺជាអង្គបុគ្គលតែមួយនោះទេ ប៉ុន្តែបេសកកម្មរបស់ អង្គទ្រង់នីមួយៗមានការរួបរួមគ្នាយ៉ាង

ខ្លាំង គឺរួបរួមនៅក្នុងសកម្មភាពនៃការប្រោសលោះ។ ព្រះយេស៊ូវជាសេចក្ដីពិត (យ៉ូហាន ១៤:៦) ហើយព្រះវិញ្ញាណនឹងដឹកនាំពួកសិស្សទៅក្នុងគ្រប់ទាំងសេចក្ដីពិត (យ៉ូហាន ១៦:១៣)។ ព្រះយេស៊ូវបានយាងមកធ្វើបន្ទាល់ឲ្យព្រះដ៏ជាព្រះវរបិតា (យ៉ូហាន ១:១៤-១៨) ហើយព្រះវិញ្ញាណបានយាងមកធ្វើបន្ទាល់ឲ្យព្រះគ្រីស្ទ (យ៉ូហាន ១៥:២៦)។ លោកិយដែលមានបាបមិនបានទទួលយកព្រះគ្រីស្ទទេ (យ៉ូហាន១:១១, ៥:៤៣) ហើយលោកិយដែលមានបាបនឹងមិនបានទទួលយកព្រះវិញ្ញាណនោះដែរ (យ៉ូហាន ១៤:១៧)។ ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះដ៏ជាជំនួយដ៏មានសិរីល្អ (យ៉ូហាន ១៤:១៦) ជាអំណាចព្រះចេស្ដានិងការមានវត្តមានលើផែនដីរបស់ព្រះគ្រីស្ទដែលបានរស់ពីសុគតនិងលើកឡើងទៅស្ថានសួគ៌វិញ។

## ការងាររបស់ព្រះវិញ្ញាណបរិសុទ្ធ

យើងបានសិក្សាហើយថា ព្រះវិញ្ញាណបរិសុទ្ធជានរណាហើយឥឡូវនេះ យើងនឹងសិក្សាអំពី “តើការងាររបស់ព្រះវិញ្ញាណជាអ្វី?”។ ផ្លូវល្អបំផុតដើម្បីស្គាល់អំពីព្រះវិញ្ញាណគឺត្រូវយល់និងមានបទពិសោធន៍ជាមួយនឹងអានុភាពរបស់ទ្រង់។ ខ្ញុំបានបែងចែកការងាររបស់ព្រះវិញ្ញាណជាប្រាំពីរប្រភេទ ព្រះវិញ្ញាណបរិសុទ្ធសំដែងអោយមនុស្សយល់, ធ្វើឲ្យជឿ, អនុវត្ត, ថ្វាយសិរីល្អ, ញែកយើងជាបរិសុទ្ធ,ប្រទានអំណោយទាន និងប្រកាសសេចក្ដីសន្យា។

## *ព្រះវិញ្ញាណបរិសុទ្ធសំដែងអោយមនុស្សយល់*

វាគួរឲ្យកត់សំគាល់ បើសិនយើងគិតអំពីការនេះ។ ព្រះយេស៊ូវចំណាយពេលពីរបីម៉ោងរបស់ទ្រង់មុនការសុគតដើម្បីបង្រៀនពួកសិស្សរបស់ទ្រង់អំពីព្រះត្រៃឯក។ ទ្រង់បានមានអារម្មណ៍ថា វាជាការចាំបាច់ក្នុងការនិយាយអំពីភាពតែមួយរបស់ទ្រង់ជាមួយព្រះវរបិតានិងការរួបរួមរបស់ទ្រង់ជាមួយព្រះវិញ្ញាណបរិសុទ្ធដែលនឹងមកដល់។ នៅក្នុងការសន្ទនាក្នុងបន្ទប់ខាងលើ ព្រះយេស៊ូវសន្យាអំពីព្រះវិញ្ញាណបរិសុទ្ធចំនួនប្រាំដង (យ៉ូហាន ១៤:១៦-១៧, ២៦, ១៥:២៦-២៧, ១៦:៤ខ-១១, ១២-១៥)។ នៅក្នុងការថ្លែងទីបួន ព្រះយេស៊ូវមានបន្ទូលអំពីការងាររបស់ព្រះវិញ្ញាណថា

> ខ្ញុំប្រាប់តាមត្រង់ថាដែលខ្ញុំទៅនោះមានប្រយោជន៍ដល់អ្នករាល់គ្នាវិញដ្បិតបើខ្ញុំមិនទៅទេនោះព្រះដ៏ជាជំនួយក៏មិនមកឯអ្នករាល់គ្នាដែរតែបើខ្ញុំទៅនោះខ្ញុំនឹងចាត់ទ្រង់ឱ្យមកកាលណាទ្រង់បានយាងមកហើយនោះទ្រង់នឹងសំដែងឱ្យមនុស្សលោកដឹងច្បាស់ពីអំពើបាបពីសេចក្ដីសុចរិតហើយពីសេចក្ដីជំនុំជំរះគឺពីអំពើបាបដោយព្រោះគេមិនជឿដល់ខ្ញុំពីសេចក្ដីសុចរិតដោយព្រោះខ្ញុំទៅឯព្រះវរបិតាខ្ញុំហើយអ្នករាល់គ្នាមិនឃើញខ្ញុំទៀតទេនឹងពីសេចក្ដីជំនុំជំរះដោយព្រោះចៅហ្វាយរបស់លោកិយនេះត្រូវទោសហើយ។
> (យ៉ូហាន ១៦:៧-១១)។

ពួកសិស្សពិបាកចិត្តដែលព្រះយេស៊ូវកំពុងចាកចេញទៅ (យ៉ូហាន ១៦:៦)។ ប៉ុន្តែព្រះយេស៊ូវធានាពួកគេថា ការដែលទ្រង់ចាកចេញទៅ នោះ

វាល្អប្រសើរ សម្រាប់ពួកគេ ពីព្រោះបើសិនទ្រង់មិនចាកចេញទៅទេ នោះព្រះវិញ្ញាណបរិសុទ្ធនឹងមិនយាងមកនោះឡើយ។ “នឹងមិន” មិនមែនដោយសារព្រះវិញ្ញាណនិងព្រះរាជបុត្រាមិនអាចគង់នៅកន្លែងដូចគ្នាបាននោះទេ ប៉ុន្តែដោយសារតែព្រះវិញ្ញាណអាចយាងមកបន្ទាប់ពីការសុគត ការរស់ពីសុគតឡើងវិញ និងការលើកឡើងទៅស្ថានសួគ៌របស់ព្រះរាជបុត្រា ។ រាជ្យរបស់ព្រះដែលចាប់ផ្តើមដោយព្រះគ្រីស្ទ នឹងបញ្ចប់ដោយព្រះវិញ្ញាណ ប៉ុន្តែបន្ទាប់ពីការងាររបស់ព្រះគ្រីស្ទបានចប់សព្វគ្រប់។

ដូច្នេះ ពួកជំនុំគឺប្រសើរជាងពីព្រោះព្រះយេស៊ូវលែងគង់នៅទីនេះជាសាច់ឈាមទៀតហើយ។ នៅសតវត្សទីមួយ អ្នកត្រូវតែទៅប៉ាឡេស្ទីនដើម្បីនៅជាមួយព្រះយេស៊ូវ។ ប៉ុន្តែឥឡូវនេះ បន្ទាប់ពីថ្ងៃបុណ្យទី៥០ ព្រះគ្រីស្ទអាចគង់នៅគ្រប់ទីកន្លែងដោយព្រះវិញ្ញាណរបស់ទ្រង់។ យើងមិនចាំបាច់ធ្វើដំណើរទៅអ៊ីស្រាអែលដើម្បីនៅជាមួយទ្រង់ ឬរស់នៅលើភ្នំ ឬដុតទៀនស្វែងរកទ្រង់នោះឡើយ។ អ្វីដែលយើងមានសព្វថ្ងៃនេះប្រសើរជាងការដើរជាមួយទ្រង់ឬមើលឃើញទ្រង់ដោយភ្នែកទៅទៀត។ ទ្រង់អាចគង់ក្នុងយើងគ្រប់ទីកន្លែងនិងគ្រប់ពេលវេលា។

វត្តមានរបស់ព្រះវិញ្ញាណគឺជាដំណឹងល្អសម្រាប់ពួកសិស្ស។ ទ្រង់នឹងជាព្រះដ៏ជាជំនួយ ព្រះដ៏កំសាន្តចិត្ត និងព្រះដ៏ការពាររបស់ពួកគេ។ ប៉ុន្តែសម្រាប់លោកិយនិងអស់អ្នកដែលនៅជាប់ក្នុងអំពើបាបវិញ នោះព្រះវិញ្ញាណនឹងសំដែងអោយមនុស្សយល់ (សូមមើលយ៉ូហាន ៣:២០ ដែលពាក្យដូចគ្នា elegcho ត្រូវបានប្រើ)។ ព្រះវិញ្ញាណបរិសុទ្ធសំដែងអំពើទុច្ចរិតរបស់លោកិយ

និងហៅមនុស្សគ្រប់ទីកន្លែងឲ្យប្រែចិត្ត។ វាដូចជាពេលយប់ដែលមនុស្សស្ថិតក្នុងភាពងងឹត នោះពួកគេអាចគិតថា ពួកគេស្ថិតក្នុងកន្លែងល្អស្អាត បន្ទាប់មកព្រះវិញ្ញាណបើកភ្លើងឲ្យពួកគេមើលឃើញសត្វកន្លាតវារលើជើងជញ្ជាំង និងសំរាមរាយប៉ាយពេញកម្រាលឥដ្ឋ។ យើងមិនល្អដូចជាយើងគិតនោះទេ ហើយព្រះវិញ្ញាណអាចបញ្ជាក់ការនេះដល់យើងបាន។

ព្រះយេស៊ូវមានបន្ទូលថា ព្រះវិញ្ញាណកាត់ទោសសំដែងអោយមនុស្សយល់អំពីបីចំនុចជាជាក់លាក់៦

១. អំពើបាប ដោយព្រោះលោកិយមិនជឿលើព្រះយេស៊ូវ។ ការមិនជឿគឺជាបេះដូងនៃអំពើបាប ហើយគ្មានសញ្ញានៃការមិនជឿណាធំជាងការបដិសេធការទទួលស្គាល់ព្រះយេស៊ូវ។

២. អំពីសេចក្តីសុចរិត ពីព្រោះព្រះយេស៊ូវបានយាងទៅឯព្រះវរបិតា។ លោកិយស្ញើចសរសើរសេចក្តីល្អរបស់ខ្លួន (អេសាយ ៦៤:៦) ប៉ុន្តែលោកិយគួរតែស្ញើចសរសើរព្រះយេស៊ូវ។ មនុស្សលោកចង់មានសិទ្ធិសម្រេចចិត្តលើ ព្រះយេស៊ូវជានរណា?ហើយសម្រេចចិត្តលើអ្វីដែលទ្រង់ពិតជាសម្រេចបាន។ ប៉ុន្តែការលើកឡើងទៅស្ថានសួគ៍វិញរបស់ទ្រង់គឺគ្រប់គ្រាន់ក្នុងការបើកសំដែងអំពីអត្តសញ្ញាណរបស់ទ្រង់ដែលជាព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ព្រះដែលជាព្រះតែមួយជាមួយនិងព្រះវរបិតា។

៣. លើការវិនិច្ឆ័យ ពីព្រោះអ្នកគ្រប់គ្រងរបស់លោកិយនេះត្រូវបាន

> វិនិច្ឆ័យហើយ។ នេះគឺជាភស្តុតាងខ្លាំងបំផុតដែលព្រះវិញ្ញាណអាចយកមកប្រឆាំងនឹងពួកយូដា ពួកគេត្រូវជឿតាមព្រះយេស៊ូវ ប៉ុន្តែគេបានសំលាប់ទ្រង់វិញហើយគេថ្វាយបង្គំអ្នកគ្រប់គ្រងក្លែងក្លាយ។ ប៉ុន្តែព្រះវិញ្ញាណនឹងយាងមកហើយធ្វើបន្ទាល់ឲ្យព្រះគ្រីស្ទដែលរស់ពីសុគតឡើងវិញ ដើម្បីឲ្យពួកគេអាចមើលឃើញថា អ្នកគ្រប់គ្រងដែលពួកគេដើរតាមត្រូវបរាជ័យ ហើយម្នាក់ដែលពួកគេបានសំលាប់បានទទួលជ័យជំនះវិញ។ ការបរាជ័យរបស់សាតាំងនៅលើឈើឆ្កាងគឺជាប្រផ្នូលនៃការបរាជ័យចុងក្រោយដែលរង់ចាំវានិងកូនចៅខាងវិញ្ញាណរបស់វា។ សាតាំងអាចនៅតែព្រុសនិងខាំ ប៉ុន្តែវាត្រូវជាប់ចំណងដោយខ្សែខ្លីហើយនឹងត្រូវវិនាស។

មុនដំបូងសេចក្តីសន្យាទាំងបីនេះបានបំពេញសម្រេចនៅថ្ងៃបុណ្យទី៥០ (កិច្ចការ ២:២២-២៤, ៣៧) ប៉ុន្តែការសំដែងអោយមនុស្សយល់នៅតែបន្ត នៅកន្លែងណាដែលមានអំពើបាបគឺត្រូវតែលាតត្រដាងនិងអត់ទោសឲ្យ។ ការងារសំដែងអោយមនុស្សយល់របស់ព្រះវិញ្ញាណគឺជាធាតុទីមួយក្នុងការកែជាថ្មីឡើងវិញ។ ព្រះវិញ្ញាណបរិសុទ្ធត្រូវតែបើកសំដែងដល់យើងនូវភាពអាត្មានិយមរបស់យើង យើងមិនមានចិត្តគោរពព្រះអម្ចាស់ ហើយយើងព្រងើយកន្តើយចំពោះព្រះគ្រីស្ទ។លោក យ៉ូណាថាន់ អេតវឺត Jonathan Edwards បានសរសេរថា:

> ព្រះវិញ្ញាណដឹកនាំមនុស្សឲ្យឈប់គិតអំពីសេចក្តីប៉ងប្រាថ្នាដ៏ឥតមានប្រយោជន៍របស់លោកិយហើយដឹកនាំពួកគេឲ្យយក

> ចិត្តទុកដាក់ខ្លាំងលើសុភមង្គលដ៏អស់កល្បជានិច្ច ដឹកនាំពួកគេឲ្យស្វែងរកសេចក្តីសង្គ្រោះរបស់ពួកគេ និងជួយឲ្យពួកគេឃើញថាបាបរបស់គេគឺជាអំពើដ៏អាក្រក់ គេមានទោសធ្ងន់ចំពោះព្រះហើយគេមិនមានសមត្ថភាពភៀសខ្លួនចេញពីអំណាចនៃអំពើបាបទេ។ វាធ្វើឲ្យបញ្ញាចិត្តរបស់មនុស្សបានដឹងថា យើងគួរឲ្យញ័រខ្លាចសេចក្តីក្រោធរបស់ព្រះ ហើយធ្វើឲ្យពួកគេមានបំណងចិត្តដ៏ធំក្នុងការទទួលយកជំនួយរបស់ព្រះ។[៧]

នៅពេលព្រះវិញ្ញាណធ្វើការក្នុងយើង នោះយើងនឹងមិនគ្រាន់តែមានសេចក្តីខ្មាសចំពោះបាបរបស់យើងឬស្តាយចំពោះកំហុសរបស់យើងប៉ុណ្ណោះនោះទេ តែមួយវិញទៀតយើងមើលឃើញថា យើងបានបះបោរប្រឆាំងនឹងព្រះហើយមានអារម្មណ៍ដូចដាវីឌនៅពេលគាត់បានស្រែកថា “ទូលបង្គំបានធ្វើបាបនឹងទ្រង់ហើយ គឺនឹងទ្រង់តែមួយព្រះអង្គ ព្រមទាំងប្រព្រឹត្តសេចក្តីដែលអាក្រក់នៅព្រះនេត្រទ្រង់ផង” (ទំនុកដំកើង ៥១:៤)។ គ្រីស្ទបរិស័ទទាំងអស់បានមើលឃើញអំពើបាបរបស់ខ្លួនដោយព្រះវិញ្ញាណបានសំដែងអោយយើងឃើញ ហើយបានមើលឃើញអំពើបាបរបស់ខ្លួនជាការប្រឆាំងនឹងព្រះដ៏មានអំណាចព្រះចេស្តា។

## *ព្រះវិញ្ញាណធ្វើឲ្យមនុស្សមានសេចក្តីជំនឿ*

យ៉ូហាន ជំពូក ៣ បានកត់ត្រាការសន្ទនារបស់ព្រះយេស៊ូវជាមួយនឹងលោកនីកូដេមដែលជាពួកផារ៉ាស៊ីនិងជាអ្នកដឹកនាំរបស់ពួកយូដា (ខ. ១)។

នេះគឺជាបទគម្ពីរល្អមួយដើម្បីបង្រៀនអំពីការប្រែចិត្តជឿ។ មិនដូចជាពួកផារ៉ាស៊ីដទៃទៀតនៅក្នុងកណ្ឌដំណឹងល្អទេ លោកនីកូដេមហាក់ដូចជាអ្នកដែលពិតជាស្វែងរកព្រះ ទោះបើគាត់កំសាកបន្តិចក៏ដោយ។ គាត់មិនប្រឆាំងនឹងព្រះយេស៊ូវនោះទេ។ ការពិត គាត់ហាក់ដូចជាមនុស្សកាន់សាសនាម្នាក់ដែលពិតជាចាប់អារម្មណ៍រៀនពីព្រះយេស៊ូវ។ លោកនីកូដេមមានតែបញ្ហាធំមួយប៉ុណ្ណោះ គឺគាត់មិនបានកើតមកពីលើ។ គាត់ទទួលស្គាល់ថា ព្រះយេស៊ូវគឺជាគ្រូបង្រៀនម្នាក់មកពីព្រះ។ គាត់បញ្ជាក់អះអាងថា ព្រះយេស៊ូវបានធ្វើការអស្ចារ្យដោយអំណាចរបស់ព្រះ (ខ. ២)។ ប៉ុន្តែការអះអាងនេះមិនទាន់គ្រប់គ្រាន់ទេ។ ព្រះយេស៊ូវមានបន្ទូលទៅកាន់គាត់ថា «ខ្ញុំមិនខ្វល់ថា អ្នកមើលឃើញការអស្ចារ្យដោយភ្នែករបស់អ្នកផ្ទាល់នោះទេ។ ខ្ញុំចង់ឲ្យព្រះធ្វើការអស្ចារ្យនៅក្នុងចិត្តរបស់អ្នកវិញ»។[៨]

ដូចជាយើងទាំងអស់គ្នាដែរ លោកនីកូដេមត្រូវតែបានកើតជាថ្មី (យ៉ូហាន ៣:៣)។ ឬយើងនិយាយតាមរបៀបផ្សេងទៀតថា យើងត្រូវតែបានកើតអំពីទឹកនិងព្រះវិញ្ញាណ (ខ. ៥)។ លោកនីកូដេមគួរតែស្គាល់រូបភាពនេះហើយពីព្រោះវាមកពីព្រះគម្ពីរសញ្ញាចាស់ (ប្រៀបធៀប ៣:១០)។ ព្រះយេស៊ូវកំពុងសំដៅទៅលើអេសេគាល ៣៦ ជាពិសេសការលើកឡើងអំពីទឹកនិងព្រះវិញ្ញាណ (អេសេគាល ៣៦:២៥, ២៧)។ នៅក្នុងទំនាយរបស់អេសេគាល ទឹកសំដៅលើការលាងសំអាត ហើយការគង់នៅរបស់ព្រះវិញ្ញាណផ្តល់ឲ្យនូវចិត្តថ្មីមួយ (៣៦:២៥-២៦)។ ដូច្នេះ ក្នុងយ៉ូហាន ជំពូក៣ ព្រះយេស៊ូវមិនមែនមានបន្ទូលអំពីបុណ្យជ្រមុជទឹកទេ ប៉ុន្តែមានបន្ទូលអំពីការអស្ចារ្យដែលលុប

ស្នាមនៃអំពើបាបចេញហើយធ្វើឲ្យយើងបានត្រឡប់ជាថ្មីវិញ។[៩]

យោងទៅតាមព្រះគម្ពីរនេះគឺជាអត្ថន័យនៃការកើតជាថ្មី ឬការកើតម្តងទៀត។ ការងាររបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងយើងជួយឲ្យយើងប្រែចិត្តជឿ។ ទីតុស ៣:៥ ហៅការនេះថា “ការសំអាតនៃសេចក្តីកើតជាថ្មី ហើយការប្រោសជាថ្មីឡើងវិញនៃព្រះវិញ្ញាណបរិសុទ្ធ”។ ដូចជាខ្យល់ (pneuma) បក់ទៅណាតាមដែលវាចង់ នោះអស់អ្នកដែលបានកើតពីព្រះវិញ្ញាណក៏ដូច្នោះដែរ (pneuma). ព្រះវិញ្ញាណបរិសុទ្ធត្រូវតែយាងចូលមកក្នុងចិត្តរបស់យើង ហើយធ្វើឲ្យយើងដឹងថា បាបរបស់យើងគឺជាអំពើដ៏អាក្រក់ ព្រះបន្ទូលព្រះគឺជាបន្ទូលដ៏ពិត និងគុណតំលៃរបស់ព្រះគ្រីស្ទ។

ព្រះយេស៊ូវបញ្ជាក់ច្បាស់លាស់ថា គ្មានជីវិតគ្រីស្ទបរិស័ទណាដែលមិនមានការងារជួយឲ្យប្រែចិត្តជឿរបស់ព្រះវិញ្ញាណនោះទេ។ ទ្រង់ជួយឲ្យយើងអាចយល់និងដឹងអំពីកិច្ចការខាងវិញ្ញាណរបស់ព្រះ (១កូរិនថូស ២:១២:១៤)។ ទ្រង់ប្រទានឲ្យយើងនូវការប្រែចិត្តដែលនាំទៅដល់ជីវិត (កិច្ចការ ១១:១៨)។ ទ្រង់ចាក់បង្ហូរសេចក្តីស្រលាញ់របស់ព្រះមកក្នុងចិត្តរបស់យើង (រ៉ូម ៥:៥)។ ទ្រង់ជួយឲ្យយើងអាចជឿលើសេចក្តីសន្យារបស់ព្រះ (យ៉ូហាន ១:១២-១៣)។ ព្រះយេស៊ូវមានបន្ទូលក្នុងយ៉ូហាន ៦:៦៥ ថា “គ្មានអ្នកណាអាចនឹងមកឯខ្ញុំបានទេ លើកតែព្រះវរបិតាទ្រង់ប្រោសប្រទានឲ្យប៉ុណ្ណោះ”។

ហើយតើពួកអ្នកដែលបានរើសតាំងមកឯព្រះបានដោយរបៀបណា? “គឺជាព្រះវិញ្ញាណដែលឲ្យមានជីវិត រូបសាច់គ្មានប្រយោជន៍អ្វីទេ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះត្រូវខាងវិញ្ញាណនិងជីវិតវិញ” (យ៉ូហាន

៦:៦៣)។ ដូច្នេះ យើងអាចមានសេចក្តីជំនឿលើព្រះរាជបុត្រាដោយសារ ព្រះវរបិតារបានរើសយើងនិងប្រទានការងាររបស់ព្រះវិញ្ញាណនៅក្នុងយើង។ ដូច្នេះ សេចក្តីជំនឿគឺជាអំណោយទានមួយដែលកើតមាននៅពេលយើងក្លាយជាគ្រីស្ទបរិស័ទ ជាពេលដែលយើងបានកើតជាថ្មីដោយព្រះវិញ្ញាណធ្វើការតាមរយៈព្រះបន្ទូលរបស់ព្រះ (២ពេត្រុស ១:២៣-២៥)។

## *ព្រះវិញ្ញាណបរិសុទ្ធអនុវត្ត*

សូមគិតអំពីគ្រប់ការទាំងអស់ដែលព្រះគ្រីស្ទបានធ្វើសម្រេចហើយ។ ទ្រង់ស្តាប់បង្គាប់តាមក្រឹត្យវិន័យ។ ទ្រង់បានយកជានិស្ស័យជាសាច់ឈាមរបស់មនុស្ស ហើយបានបំពេញសម្រេចសេចក្តីយុត្តិធម៌របស់ព្រះ។ ទ្រង់បានឈ្នះសេក្តីស្លាប់ អំពើបាប និងសាតាំង។ ក្នុងនាមជាព្រះមែស្ស៊ីដែលរក្សាសម្ព័ន្ធមេត្រី ទ្រង់បានប្រទានគ្រប់ទាំងព្រះពរខាងវិញ្ញាណសម្រាប់រាស្ត្ររបស់ទ្រង់ (អេភេសូរ ១:៣)។ ព្រះយេស៊ូវគ្រីស្ទគឺជាប្រាជ្ញា សេចក្តីសុចរិត ការញែកជាបរិសុទ្ធ និងសេចក្តីប្រោសលោះ (១កូរិនថូស ១:៣០)។

ការរួបរួមជាមួយព្រះគ្រីស្ទ។ ប៉ុន្តែតើគ្រប់ទាំងអស់ដែលព្រះគ្រីស្ទបានសម្រេចបានត្រឡប់ជារបស់យើងដោយរបៀបណា? នេះគឺជាសំនួរមួយដែលយើងភាគច្រើនមិនដែលបានគិតពិចារណា។ បណ្ឌិត ចន កាលវិន សួរថា:

តើយើងទទួលបានគុណប្រយោជន៍ដែលព្រះវរបិតាបានប្រទានឲ្យព្រះរាជបុត្រាស្ងួនភ្ងាតែមួយរបស់ទ្រង់ មិនមែនសម្រាប់ការប្រើផ្ទាល់ខ្លួនរបស់ព្រះគ្រីស្ទនោះទេ តែសម្រាប់ទ្រង់យកទៅជួយមនុស្សក្រីក្រឲ្យរីកចំរើនឡើង ដោយ

របៀបណា? ទីមួយ យើងត្រូវតែយល់ថា ដរាបណាព្រះគ្រីស្ទគង់នៅខាងក្រៅយើង ហើយយើងដាច់ចេញពីទ្រង់ នោះគ្រប់ការទាំងអស់ដែលទ្រង់បានរងទុក្ខនិងបានធ្វើសម្រាប់សេចក្តីសង្គ្រោះមនុស្សជាតិនៅតែគ្មានប្រយោជន៍និងគ្មានគុណតំលៃសម្រាប់យើងនៅឡើយ។[១០]

ដូច្នេះ តើយើងមានចំណែកក្នុងគុណប្រយោជន៍របស់ព្រះគ្រីស្ទដោយរបៀបណា? បណ្ឌិត ចនកាលវិន ឆ្លើយថា “ព្រះវិញ្ញាណបរិសុទ្ធគឺជាចំណងដែលព្រះពង្រួបពង្រួមយើងជាមួយនឹងអង្គទ្រង់ដោយមានប្រសិទ្ធិភាព”។[១១]

នៅក្នុងរ៉ូម ៨:៩-១១ ប៉ុលបង្រៀនសេចក្តីពិតស្រដៀងគ្នា។ នៅពេលព្រះវិញ្ញាណគង់ក្នុងយើង នោះយើងមានព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ (ខ. ១០) ហើយបើសិនព្រះវិញ្ញាណគង់ក្នុងយើង នោះយើងនឹងមានជីវិតនៅក្នុងព្រះយេស៊ូវគ្រីស្ទ (ខ. ១១)។ ដូច្នេះ នៅពេលអ្នកមានព្រះវិញ្ញាណ នោះអ្នកមានព្រះគ្រីស្ទ ហើយនៅពេលអ្នកមានព្រះគ្រីស្ទ នោះអ្នកមានព្រះវិញ្ញាណ។ ព្រះវិញ្ញាណបរិសុទ្ធពង្រួបពង្រួមយើងជាមួយព្រះគ្រីស្ទ ពីព្រោះព្រះវិញ្ញាណគឺជាព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ។ ទ្រង់គឺជាព្រះវិញ្ញាណនៃការទទួលជាកូនចិញ្ចឹមដែលធ្វើឲ្យយើងត្រឡប់ជាកូនរបស់ព្រះវរបិតាដោយការពង្រួបពង្រួមយើងជាមួយបងប្រុសរបស់យើងគឺ ព្រះគ្រីស្ទ (រ៉ូម ៨:១៥ កាឡាទី ៤:៦ ហេព្រឺ ២:១៧)។ តាមរយៈព្រះវិញ្ញាណ ព្រះបានយកយើងចេញពីក្រុមរបស់ “អ័ដាមទីមួយ” ហើយដាក់យើងទៅក្នុងក្រុមរបស់ “អ័ដាមទីពីរ”។

ជារឿយៗយើងមិនគិតអំពីចំនុចនៃសេចក្តីប្រោសលោះនេះទេ ប៉ុន្តែលោកយ៉ូហាន មឺរី John Murray និយាយថា ការរួបរួមជាមួយព្រះគ្រីស្ទគឺជា “សេចក្តី

ពិតស្នូលនៃសេចក្ដីពិតអំពីសេចក្ដីសង្គ្រោះ»។[១២] លោកប៉ុលប្រើពាក្យ «ក្នុងព្រះគ្រីស្ទ» ចំនួន១៦០ដង[១៣] ដែលបង្ហាញថា ការរួបរួមរបស់យើងជាមួយព្រះគ្រីស្ទមានសារៈសំខាន់ខ្លាំងណាស់។ គ្រប់ទាំងការរាប់ជាសុចរិត ការផ្សះផ្សា សេចក្ដីប្រោសលោះ ការទទួលជាកូនចិញ្ចឹម ការញែកជាបរិសុទ្ធ ការថ្វាយសិរីល្អជារបស់យើងដោយព្រោះតែយើងបានរួបរួមជាមួយព្រះគ្រីស្ទ។ ព្រះគ្រីស្ទគង់ក្នុងយើងដោយព្រះវិញ្ញាណក្នុងរបៀបអស្ចារ្យដើម្បីឲ្យយើងអាចមានទំនាក់ទំនងជាមួយព្រះគ្រីស្ទហើយបានទទួលគុណប្រយោជន៍ទាំងអស់របស់ទ្រង់។

ការទទួលបុណ្យជ្រមុជដោយព្រះវិញ្ញាណជាការរួបរួមរបស់យើងជាមួយព្រះគ្រីស្ទ។ យើងត្រូវតែសិក្សាអំពីបទគម្ពីរពិសេសមួយទៀតៈ «ដ្បិតយើងទាំងអស់គ្នាទោះបើជាសាសន៍យូដា ឬសាសន៍ក្រិក បាវបម្រើ ឬអ្នកជាក្ដី យើងបានទទួលបុណ្យជ្រមុជ ចូលក្នុងរូបកាយតែមួយ ដោយសារព្រះវិញ្ញាណតែមួយ ហើយគ្រប់គ្នាក៏បានត្រូវផឹកពីព្រះវិញ្ញាណតែមួយដែរ» (១កូរិនថូស ១២:១៣)។ ពួកគ្រីស្ទបរិស័ទបន្តពិភាក្សាអំពីអត្ថន័យរបស់ខគម្ពីរមួយនេះ។ តើការទទួលបុណ្យជ្រមុជនេះជាការមួយដែលគ្រីស្ទបរិស័ទទាំងអស់ទទួលបាន ឬជាព្រះពរមួយដែលមានតែគ្រីស្ទបរិស័ទខ្លះទេដែលទទួលបាន?

ចំលើយគឺត្រង់៖ ឃ្លា «ការទទួលបុណ្យជ្រមុជក្នុង/ ដោយព្រះវិញ្ញាណ» (enpneumati) លេចឡើងចំនួនប្រាំពីរដងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ ការលេចឡើងបួនដងគឺនៅក្នុងកណ្ឌដំណឹងល្អដែលយ៉ូហាន-បាទីស្ទទាយថាព្រះអម្ចាស់យេស៊ូវនឹងធ្វើបុណ្យជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ (ម៉ាថាយ ៣:១១ ម៉ាកុស ១:៨ លូកា ៣:១៦ យ៉ូហាន ១:៣៣)។ ការលេចឡើងទីប្រាំ

គឺនៅក្នុងកិច្ចការ ១:៥ ដែលព្រះយេស៊ូវសំដៅទៅលើការទាយរបស់យ៉ូហាន។ ការលេចឡើងទីប្រាំមួយគឺនៅក្នុងកិច្ចការ ១១:១៦ នៅពេលពេត្រុសរំលឹកអំពីព្រះបន្ទូលរបស់ព្រះយេស៊ូវ ចាប់តាំងពីមុនការលើកឡើងទៅស្ថានសួគ៌វិញរបស់ទ្រង់នៅក្នុងកិច្ចការ ១:៥។ ដូច្នេះ ការលេចឡើងទាំងប្រាំមួយនេះដែលទាក់ទងនឹងការទទួលបុណ្យជ្រមុជក្នុង/ដោយព្រះវិញ្ញាណទន្ទឹងរង់ចាំ ឬងាកបែរទៅការដដែលគឺ ការចាក់បង្ហូរព្រះវិញ្ញាណនៅថ្ងៃបុណ្យទី៥០។

បទគម្ពីរទីប្រាំពីរ ១កូរិនថូស ១២:១៣ គឺពិសេសដោយឡែក ពីព្រោះវាមិនសំដៅផ្ទាល់ទៅលើថ្ងៃបុណ្យទី ៥០នោះទេ (ពួកកូរិនថូសនិងប៉ុលមិនបាននៅទីនោះដើម្បីទទួលបុណ្យជ្រមុជដោយព្រះវិញ្ញាណនៅក្នុងក្រុងយេរូសាឡឹមនោះទេ)។ ដូច្នេះ គ្រីស្ទបរិស័ទខ្លះ បានបង្រៀនថា ១កូរិនថូស ១២:១៣ និយាយអំពីបទពិសោធន៍ព្រះពរទីពីរដែលមកបន្ទាប់ពីការប្រែចិត្តជឿហើយថាមានតែគ្រីស្ទបរិស័ទខ្លះប៉ុណ្ណោះដែលអាចទទួលបាន។ ប៉ុន្តែទស្សនៈនេះដែលជឿលើព្រះពរទីពីរមិនត្រឹមត្រូវនោះទេ។ ទីមួយ ខគម្ពីរនេះសង្កត់ធ្ងន់ថា គ្រប់គ្នាបានទទួលបុណ្យជ្រមុជនៅក្នុង(ដោយ)ព្រះវិញ្ញាណ ហើយគ្រប់គ្នាត្រូវបានផឹកពីព្រះវិញ្ញាណ។

មិនខ្វល់ថាប៉ុលកំពុងតែនិយាយអំពីអ្វីនោះទេ វាច្បាស់លាស់ណាស់ថាគាត់បានសន្មត់ថា គ្រីស្ទបរិស័ទទាំងអស់នៅក្រុងកូរិនថូសបានទទួលការជ្រមុជនេះ។ លើសពីនេះ តាមបរិបទធំជាងនេះ ប៉ុលមិនអាចកំពុងនិយាយអំពីព្រះពរពិសេសទីពីរមួយដែលមានតែគ្រីស្ទបរិស័ទខ្លះអាចទទួលបាននោះទេ។ បន្ទាប់ពីការសង្កត់ធ្ងន់លើភាពខុសគ្នានៃអំណោយទាននៅក្នុងរូបកាយ ប៉ុលងាកមក

ផ្តោតលើការរួបរួមរបស់គ្រីស្ទបរិស័ទ។ ពួកគេមានអំណោយទានខុសៗគ្នា ប៉ុន្តែពួកគេគ្រប់គ្នាបានទទួលបុណ្យជ្រមុជនៅក្នុង(ដោយ)ព្រះវិញ្ញាណតែមួយ។

ការទទួលបុណ្យជ្រមុជដោយព្រះវិញ្ញាណគឺជាការមួយដែលគ្រីស្ទបរិស័ទគ្រប់រូបបានទទួលហើយ ដោយព្រោះគ្រីស្ទបរិស័ទគ្រប់រូបបានកើតជាថ្មីនិងរួបរួមជាមួយព្រះគ្រីស្ទតាមរយៈការដែលព្រះវិញ្ញាណបរិសុទ្ធគង់នៅក្នុងយើង។ ការទទួលបុណ្យជ្រមុជដោយព្រះវិញ្ញាណស្មើនឹងការរួបរួមរបស់យើងជាមួយព្រះគ្រីស្ទ។ ព្រះ វិញ្ញាណដដែលត្រូវចាក់បង្ហូរជាដំបូងនៅថ្ងៃបុណ្យទី៥០ ឥឡូវគង់នៅក្នុងអ្នកជឿគ្រប់រូប ហើយពង្រួបពង្រួមយើងជាមួយព្រះគ្រីស្ទនិងជ្រមុជយើងទៅក្នុងគ្រប់ទាំងព្រះពររបស់ទ្រង់។

ព្រះយេស៊ូវធ្វើពិធីជ្រមុជឲ្យយើង ដោយព្រះវិញ្ញាណដើម្បីឲ្យយើងអាចស្គាល់អំណាចព្រះចេស្តារបស់ទ្រង់និងទទួលបានព្រះពរដ៏បរិបូណ៌របស់ទ្រង់។ ឬដូចជាលោក ចន ស្តោត John Stott សង្ខេបថា ការទទួលពិធីជ្រមុជដោយព្រះវិញ្ញាណគឺជាព្រះពរមួយដែលកើតមាននៅក្នុងតែសម្ព័ន្ធមេត្រីថ្មីប៉ុណ្ណោះ គឺជាព្រះពរដំបូង (ដែលយើងទទួលបាននៅពេលយើងប្រែចិត្តជឿ) ហើយជាព្រះពរដែលបានចាក់បង្ហូរលើអ្នកជឿពិតប្រាកដនិមួយៗ)។[១៤]

## *ព្រះវិញ្ញាណបរិសុទ្ធថ្វាយសិរីល្អ*

នៅក្នុងចំណងជើងរងនេះ អ្នកប្រហែលគិតថា ខ្ញុំនឹងបន្តនិយាយអំពី «លំដាប់នៃសេចក្តីសង្គ្រោះ» ហើយពន្យល់អំពីរបៀបដែលព្រះវិញ្ញាណដឹកនាំគ្រីស្ទបរិស័ទទៅកាន់សិរីល្អចុងក្រោយ។ ប៉ុន្តែវាមិនមែនជាគំនិតរបស់ខ្ញុំនោះទេ

ដោយព្រោះវាមិនមែនជាអ្វីដែលព្រះយេស៊ូវមានបន្ទូលនៅក្នុងយ៉ូហានជំពូក ១៤-១៧។ នៅក្នុងសេចក្តីសន្យាទីប្រាំមួយរបស់ព្រះយេស៊ូវទាក់ទងនឹងព្រះវិញ្ញាណបរិសុទ្ធ ទ្រង់មានបន្ទូលអំពីសិរីល្អថា:

> កាលណាព្រះអង្គនោះគឺជាព្រះវិញ្ញាណនៃសេចក្តីពិតបានមកដល់នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្តីពិតដ្បិតទ្រង់នឹងមានបន្ទូលមិនមែនដោយអាងព្រះអង្គទ្រង់ទេគឺនឹងមានបន្ទូលចំពោះតែសេចក្តីណាដែលទ្រង់ឮហើយនឹងសំដែងឱ្យអ្នករាល់គ្នាដឹងការដែលត្រូវមកទ្រង់នឹងដំកើងខ្ញុំដ្បិតទ្រង់នឹងយកសេចក្តីដែលដំរូវពីខ្ញុំមកប្រាប់ដល់អ្នករាល់គ្នាគ្រប់ទាំងអស់ដែលព្រះវរបិតាមាននោះជារបស់ផងខ្ញុំដែរហេតុនោះបានជាខ្ញុំប្រាប់ថាទ្រង់នឹងយកសេចក្តីដែលដំរូវពីខ្ញុំមកប្រាប់អ្នករាល់គ្នា។
> (យ៉ូហាន១៦:១៣-១៥)

នៅទីនេះយើងមានព្រះបន្ទូលចុងក្រោយរបស់ព្រះយេស៊ូវអំពីព្រះវិញ្ញាណបរិសុទ្ធនៅពេលទ្រង់យាងមកឯឈើឆ្កាង តើព្រះយេស៊ូវសង្កត់ធ្ងន់លើអ្វី? គឺជាការងាររបស់ព្រះវិញ្ញាណក្នុងថ្វាយសិរីល្អដល់(លើកដំកើង)ព្រះគ្រីស្ទជារឿយៗយើងព្រងើយកន្តើយចំពោះការងារដ៏សំខាន់របស់ព្រះវិញ្ញាណបរិសុទ្ធនេះ។ ទីមួយ ព្រះយេស៊ូវកំពុងមានបន្ទូលទៅកាន់សាវ័កទាំងដប់ពីរអំពីការងារដែលព្រះវិញ្ញាណនឹងធ្វើនៅក្នុងជីវិតរបស់ពួកគេនៅថ្ងៃបន្ទាប់ៗមកទៀតដើម្បីបើកសំដែងសិរីល្អពេញលេញរបស់ព្រះគ្រីស្ទទៅកាន់ពួកគេ (យ៉ូហាន ៧:៣៩)។ ប៉ុន្តែលើសពីនេះ សេចក្តីសន្យារបស់ព្រះយេស៊ូវក៏និយាយ

អំពីការងាររបស់ព្រះវិញ្ញាណក្នុងការថ្វាយសិរីល្អដល់ព្រះគ្រីស្ទនៅក្នុងចិត្តរបស់យើងតាមរយៈសេចក្តីពិតដែលពួកសិស្សនឹងមើលឃើញក្នុងពេលឆាប់ៗ។ នេះជាបទគម្ពីរសំខាន់មួយ ពីព្រោះវាជួយយើងឲ្យជៀសវាងកំហុសធម្មតាពីរ។

កំហុសទីមួយគឺការធ្វើឲ្យព្រះវិញ្ញាណនិងព្រះគម្ពីរប្រកួតប្រឆាំង គ្នាទៅវិញទៅមក។ ព្រះយេស៊ូវមិនសន្យាថា ព្រះវិញ្ញាណនឹងប្រាប់ខ្ញុំពីអ្នកណាដែលខ្ញុំគួរតែរៀបការជាមួយ ឬពីការងារអ្វីដែលខ្ញុំគួរតែធ្វើនោះទេ។ នេះមិនមែនជាអ្វីដែលទ្រង់ចង់មានន័យទេនៅពេលទ្រង់មានបន្ទូលថា ព្រះវិញ្ញាណ "នឹងនាំអ្នករាល់គ្នាចូលទៅក្នុងគ្រប់ទាំងសេចក្តីពិត" (យ៉ូហាន ១៦:១៣)។ ព្រះយេស៊ូវកំពុងមានបន្ទូលទៅកាន់ពួកសាវ័ក (ខ. ១២)។ ពួកគេគឺជាមនុស្សដែលព្រះវិញ្ញាណនឹងនាំចូលទៅក្នុង "គ្រប់ទាំងសេចក្តីពិត"។

"គ្រប់ទាំងសេចក្តីពិត" ដែលពួកគេនឹងទទួលបានមិនមែនជាសេចក្តីពិតអំពីគ្រប់ទាំងចំណេះដឹងនៅក្នុងសកលលោកនោះទេ។ "សេចក្តីពិត" សំដៅលើសេចក្តីពិតទាំងស្រុងអំពីព្រះយេស៊ូវគ្រីស្ទដែលជាផ្លូវ ជាសេចក្តីពិត និងជាជីវិត។ ព្រះវិញ្ញាណនឹងបំភ្លឺការដែលត្រូវមក (យ៉ូហាន ១៦:១៣) មិនមែនក្នុងគំនិតទាយទេ ប៉ុន្តែនៅពេលទ្រង់នឹងបើកសំដែងអំពីខ្លឹមសាររបស់ព្រឹត្តិការណ៍ដែលមិនទាន់នឹងមកដល់នៅឡើយគឺ ការសុគត ការរស់ពីសុគតឡើងវិញ ការលើកតម្កើងរបស់ព្រះយេស៊ូវ។ ដោយមានបន្ទូលនៃព្រះវរបិតានិងព្រះរាជបុត្រា នោះព្រះវិញ្ញាណនឹងជួយឲ្យពួកសាវ័កចងចាំនូវអ្វីដែលព្រះយេស៊ូវបានមានបន្ទូល ហើយជួយឲ្យយល់អត្ថន័យពិតប្រាកដថាព្រះយេស៊ូវជានរណា និងអ្វីដែលទ្រង់សម្រេចបាន (យ៉ូហាន ១៤:២៦)។

នេះមានន័យថា ព្រះវិញ្ញាណបាននាំមកឯពួកសាវ័កនូវសេចក្ដីពិតដែលពួកគេអធិប្បាយនិងបានសរសេរចុះក្នុងព្រះគម្ពីរសញ្ញាថ្មី។ យើងជឿទុកចិត្តព្រះគម្ពីរដោយព្រោះពួកសាវ័កនិងអស់អ្នកដែលនៅក្រោមអំណាចរបស់ពួកគេបានសរសេរតាមរយៈការបើកសំដែងរបស់ព្រះវិញ្ញាណ។ ព្រះគម្ពីរគឺជាសៀវភៅរបស់ព្រះវិញ្ញាណ។ ពួកសាវ័កបានបង្រៀនថា ព្រះវិញ្ញាណបរិសុទ្ធបានបណ្ដាលឲ្យសរសេរព្រះគម្ពីរសញ្ញាចាស់ (កិច្ចការ ៤:២៥, ២៨:២៥, ហេព្រឺ ៣:៧, ២ពេត្រុស ១:២១) ហើយក៏បណ្ដាលឲ្យសរសេរព្រះគម្ពីរសញ្ញាថ្មីផងដែរ ដូចជាព្រះយេស៊ូវបានសន្យាក្នុងយ៉ូហាន ជំពូក១៦។

ដូច្នេះ យើងមិនអាចទទួលយកសេចក្ដីបង្រៀនរបស់អស់អ្នក(ដូចជាម៉័រមិន)ដែលបង្រៀនថា មានការបើកសំដែងបន្ដដែលបន្ថែមទៅក្នុងមាតិការបស់ព្រះគម្ពីរសញ្ញាថ្មីនោះទ ឬយើងមិនអាចយល់ស្របជាមួយនឹងទស្សនៈដែលថា គ្រីស្ទបរិស័ទដែលចង់ស្ដាប់ព្រះបន្ទូលរបស់ព្រះតែក្នុងព្រះគម្ពីរប៉ុណ្ណោះ (គឺគេមិនស្វែងរកព្រះបន្ទូលនៅកន្លែងក្រៅពីព្រះគម្ពីរ)គឺជាការប្រមាថដល់ព្រះវិញ្ញាណបរិសុទ្ធទេ។ ព្រះបន្ទូលនិងព្រះវិញ្ញាណជាដៃគូដែលមិនអាចបំបែកបានទេ។ យើងស្ដាប់ឮពីព្រះវិញ្ញាណនៅពេលយើងអានព្រះគម្ពីរ ហើយក្នុងការអានព្រះគម្ពីរ នោះយើងត្រូវតែអធិស្ឋានសូមការបំភ្លឺរបស់ព្រះវិញ្ញាណ។

កំហុសទីពីរដែលបទគម្ពីរនេះអាចជួយឲ្យយើងជៀសវាងគឺជា ការធ្វើឲ្យព្រះវិញ្ញាណនិងព្រះគ្រីស្ទប្រកួតប្រឆាំងគ្នាទៅវិញទៅមក។ ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះវិញ្ញាណបម្រើ។ ទ្រង់មានបន្ទូលតែអ្វីដែលទ្រង់បានឮ (យ៉ូហាន ១៦:១៣)។ ទ្រង់ប្រកាសអ្វីដែលត្រូវបានប្រទានមកឲ្យទ្រង់ ហើយបេសកកម្ម

របស់ទ្រង់គឺត្រូវថ្វាយសិរីល្អដល់មួយអង្គទៀត (ខ. ១៤)។ អង្គបុគ្គលទាំងបីនៅក្នុងព្រះត្រៃឯកគឺជាព្រះ ហើយព្រះរាជបុត្រាធ្វើឲ្យគេស្គាល់ព្រះវរបិតា ហើយព្រះវិញ្ញាណថ្វាយសិរីល្អដល់ព្រះរាជបុត្រា។ បាទ វាគួរឲ្យសោកសង្រេងដែលយើងព្រងើយកន្តើយនឹងព្រះវិញ្ញាណបរិសុទ្ធនិងមើលរំលងតួនាទីសំខាន់ដែលទ្រង់មាននៅក្នុងជីវិតរបស់យើង។ ប៉ុន្តែយើងមិនអាចផ្តោតលើព្រះគ្រីស្ទច្រើនពេកនោះទេ។ ព្រះវិញ្ញាណមិនឈឺចាប់នោះទេ នៅពេលយើងចាប់អារម្មណ៍លើព្រះគ្រីស្ទនោះ។

ការត្រេកអរក្នុងព្រះគ្រីស្ទបង្ហាញថា ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់យើង! ការផ្តោតរបស់ពួកជំនុំមិនមែននៅលើសត្វព្រាប(ព្រះវិញ្ញាណបរិសុទ្ធ)ទេ ប៉ុន្តែលើឈើឆ្កាងវិញ ហើយនេះស្របគ្នានឹងព្រះហឫទ័យរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ដូចជាលោក ផាក់ខឺ J. I. Packer និយាយថា ព្រះវិញ្ញាណមិនដែលមានបន្ទូលមកកាន់យើងថា «ចូរមើលមកខ្ញុំ ចូរស្តាប់តាមខ្ញុំ ចូរមកឯខ្ញុំ ចូរស្គាល់ខ្ញុំ» ប៉ុន្តែតែងតែនិយាយដូចនេះថា «ចូរមើលមកព្រះគ្រីស្ទ ហើយឃើញសិរីល្អរបស់ព្រះគ្រីស្ទ ចូរស្តាប់តាមព្រះគ្រីស្ទ និងឮព្រះបន្ទូលព្រះគ្រីស្ទ ចូរទៅឯព្រះគ្រីស្ទ ហើយមានជីវិត ចូរស្គាល់ព្រះគ្រីស្ទ ហើយទទួលយកអំណោយទាននៃសេចក្តីអំណរនិងសន្តិភាពរបស់ទ្រង់ចុះ»។[១៥]

សេចក្តីពិតដែលថាការងាររបស់ព្រះវិញ្ញាណគឺត្រូវបើកសំដែងនិងថ្វាយសិរីល្អដល់ព្រះរាជបុត្រា បង្ហាញអំពីកំហុសរបស់ទស្សនៈមួយទៀត។ ខ្ញុំចងចាំអំពីសាស្ត្រាចារ្យម្នាក់នៅក្នុងមហាវិទ្យាល័យដែលបានបង្រៀនថា ដោយព្រោះព្រះមានអធិបតីភាពហើយព្រះវិញ្ញាណបក់ទៅទីណាដែលទ្រង់ចង់ នោះ

ព្រះវិញ្ញាណអាចកំពុងសង្គ្រោះមនុស្សពីក្នុងគ្រប់សាសនាទាំងអស់ បណ្តាលឲ្យមនុស្សបានកើតជាថ្មីហើយពង្រួបពង្រួមមនុស្សជាមួយនឹងព្រះគ្រីស្ទទោះបើពួកគេមិនដឹងពីការនេះក៏ដោយ។ គាត់បានជឿថា មនុស្សអាចបានសង្គ្រោះដោយមិនចាំបាច់ឮអំពីព្រះគ្រីស្ទឬមានជំនឿលើទ្រង់នោះឡើយ។ ទស្សនៈនេះមានប្រជាប្រិយភាព។ សូម្បីតែលោក លូអ៊ីសC. S. Lewisជាទីស្រលាញ់ក៏បានជឿទស្សនៈនេះដែរៈ

> មានមនុស្សដែលមិនទទួលយកគោលលិទ្ធិគ្រីស្ទបរិស័ទអំពីព្រះគ្រីស្ទទាំងស្រុង ប៉ុន្តែព្រះគ្រីស្ទទាក់ទាញពួកគេយ៉ាងខ្លាំងដែលពួកគេគឺជារបស់ទ្រង់នៅក្នុងន័យមួយជ្រៅខ្លាំងជាងពួកគេយល់។ មានមនុស្សនៅក្នុងសាសនាផ្សេងៗទៀតដែលកំពុងត្រូវបានដឹកនាំដោយឥទ្ធិពលអាថ៌កំបាំងរបស់ព្រះឲ្យផ្តោតលើផ្នែកណារបស់សាសនារបស់ពួកគេដែលយល់ស្របជាមួយជំនឿគ្រីស្ទបរិស័ទ ហើយពួកគេគឺជារបស់ព្រះគ្រីស្ទ ទោះបីជាគេមិនដឹងថាគេជារបស់ព្រះគ្រីស្ទក៏ដោយ។ ជាឧទាហរណ៍ ពុទ្ធបរិស័ទម្នាក់ដែលមានឆន្ទៈល្អអាចសញ្ជឹងគិតលើសេចក្តីបង្រៀនរបស់ពុទ្ធិសាសនាអំពីសេចក្តីមេត្តាករុណា ហើយមិនសូវចាប់អារម្មណ៍អំពីសេចក្តីបង្រៀនពុទ្ធិសាសនាផ្សេងៗទៀត (ទោះបើគាត់នៅតែនិយាយថាគាត់បានជឿក៏ដោយ)។[១៦]

ជារឿយៗខ្ញុំទទួលបានគុណប្រយោជន៍ពីលោកលូអ៊ីស ប៉ុន្តែគិតក្នុងរបៀបនេះគឺយល់ខុសអំពីបេសកកម្មរបស់ព្រះវិញ្ញាណនៅថ្ងៃបុណ្យទី ៥០ និងក្នុង

សម័យនេះ។ ការងាររបស់ព្រះវិញ្ញាណបរិសុទ្ធគឺត្រូវនាំសិរីល្អដល់ព្រះគ្រីស្ទ ដោយយកអ្វីដែលជារបស់ទ្រង់ សេចក្តីបង្រៀនរបស់ទ្រង់ សេចក្តីពិតអំពីការសុគតនិងការរស់ពីសុគតឡើងវិញរបស់ទ្រង់ហើយធ្វើឲ្យគេបានដឹងអំពីការទាំងនេះ។ ព្រះវិញ្ញាណមិនធ្វើការដោយមិនមានគោលដៅបើកសំដែងអំពីព្រះគ្រីស្ទនោះទេ។ ប្រហែលជាការងារសំខាន់បំផុតរបស់ព្រះវិញ្ញាណបរិសុទ្ធគឺត្រូវថ្វាយសិរីល្អដល់ព្រះគ្រីស្ទ ហើយទ្រង់មិនធ្វើការនេះដោយគ្មានការបញ្ចេញពន្លឺនៅលើព្រះគ្រីស្ទឲ្យពួកមនុស្សដែលព្រះជ្រើសរើសបានមើលឃើញនោះឡើយ។

## *ព្រះវិញ្ញាណបរិសុទ្ធញែកយើងជាបរិសុទ្ធ*

ការជំរាបសួរដំបូងក្នុងសំបុត្រទីមួយរបស់ពេត្រុសបានបង្រៀនយ៉ាងច្បាស់ថាព្រះអង្គទាំងបីនៅក្នុងព្រះត្រៃឯកមានតួនាទីក្នុងសេចក្តីសង្គ្រោះរបស់យើង។ ព្រះជាម្ចាស់បានជ្រើសរើសយើង តាមគំរោងការដែលព្រះអង្គគ្រោងទុកពីមុនមក ដោយព្រះវិញ្ញាណប្រោសយើងអោយបានបរិសុទ្ធ ដើម្បីអោយយើងស្តាប់បង្គាប់ព្រះយេស៊ូវគ្រីស្ទ និងអោយព្រះអង្គប្រោះព្រះលោហិតរបស់ព្រះអង្គលើយើង (១ពេត្រុស ១:២)។ ព្រះ វិញ្ញាណបរិសុទ្ធញែកយើងជាបរិសុទ្ធតាមរបៀបពីរ។ ទីមួយ ទ្រង់ញែកយើងឲ្យបាននៅក្នុងព្រះគ្រីស្ទដើម្បីឲ្យយើងអាច បានស្អាតដោយព្រះលោហិតរបស់ទ្រង់។ ទីពីរ ទ្រង់ធ្វើការក្នុងយើងដើម្បីឲ្យយើងអាចស្តាប់បង្គាប់ដល់ព្រះយេស៊ូវគ្រីស្ទ។ តាមរយៈការញែកជាបរិសុទ្ធរបស់ព្រះវិញ្ញាណ នោះយើងទទួលបានឋានៈថ្មី(របៀបទីមួយខាងលើ)

និងកំលាំងថ្មី(របៀបទីពីរខាងលើ)។

នៅពេលយើងសិក្សាអំពីការញែកជាបរិសុទ្ធ ជាញឹកញាប់យើងគិតអំពីរបៀបទីពីរខាងលើគឺជាកំលាំងថ្មីដើម្បីឲ្យយើងអាចស្តាប់បង្គាប់ដល់ព្រះយេស៊ូវគ្រីស្ទ។ ទោះបើយើងទទួលបានឋានៈថ្មីភ្លាមនៅពេលព្រះញែកយើងជាបរិសុទ្ធក៏ដោយ ក៏នៅក្នុងទេវសាស្រ្តធម្មតាយើងប្រើពាក្យ“ញែកជាបរិសុទ្ធ”ដើម្បីសំដៅលើជីវិតបរិសុទ្ធរបស់យើងដែលមានការរីកចំរើនទៅមុខ គឺជារបៀបដែលព្រះធ្វើការក្នុងយើងសម្រាប់សិរីល្អរបស់ទ្រង់នៅពេលយើងបង្ហើយជីវិតនៃសេចក្តីសង្រ្គោះដោយកោតខ្លាចនិងញាប់ញ័រ (ភីលីព ២:១២-១៣)។ ឬដូចជារ៉ូម ៨:៩-១៣ និយាយថា យើងលែងស្ថិតក្នុងសាច់ឈាមទៀតហើយ ប៉ុន្តែក្នុងព្រះវិញ្ញាណវិញ (កន្លែង) ដូច្នេះ តាមរយៈព្រះវិញ្ញាណ នោះយើងគួរតែសំលាប់ទង្វើរខាងសាច់ឈាម (អំណាច) ចោលទៅ។

ថ្វីបើយើងត្រូវតែខិតខំឲ្យការគោរពព្រះអម្ចាស់របស់យើងមានការរីកចំរើន (២ពេត្រុស ១:៥) ក៏ព្រះវិញ្ញាណជួយឲ្យយើងអាចធ្វើការនេះបានដែរ។ ព្រះគម្ពីរមិនគ្រាន់តែប្រាប់យើងឲ្យផ្លាស់ប្រែនិងលើកទឹកចិត្តយើងថា “អ្នកអាចផ្លាស់ប្រែបាន!” ប៉ុណ្ណោះទេ។ យើងត្រូវបានផ្លាស់ប្រែរួចរាល់ហើយ។ យើងគឺជាស្នាព្រះហស្តថ្មីនៅក្នុងព្រះគ្រីស្ទ (២កូរិនថូស ៥:១៧) ហើយយើងមានកំលាំងថ្មីធ្វើការនៅខាងក្នុងយើង (អេភេសូរ ៣:១៦) បង្កើតផលផ្លែដំណឹងល្អនៅក្នុងយើងដោយព្រះវិញ្ញាណ (កាឡាទី ៥:២២-២៣)។ ព្រះគម្ពីររំពឹងចង់បានថា ដោយសារព្រះគង់ក្នុងយើងដោយព្រះវិញ្ញាណ នោះដោយព្រះវិញ្ញាណដដែលយើងអាចចាប់ផ្តើមមានគុណភាពដែលគោរពតាមចរិតលក្ខណៈនៃព្រះ

(២ពេត្រុស ១:៤)។ តាមពិត នៅតែមានការតយុទ្ធនៅខាងក្នុងខ្លួនយើង។ ប៉ុន្តែ យើងអាចមានការរីកចំរើននិងជ័យជំនះពិតប្រាកដតាមរយៈព្រះវិញ្ញាណ។ ព្រះគម្ពីរសញ្ញាថ្មីគ្រាន់តែហៅឲ្យយើងធ្វើជាមនុស្សដែលស្របតាមឋានៈថ្មី ដែលព្រះអង្គប្រទានអោយ(គឺជាកូនរបស់ព្រះ)ប៉ុណ្ណោះ។

តើព្រះវិញ្ញាណ ជួយឲ្យយើងរីកចំរើនក្នុងការគោរពព្រះអម្ចាស់ដោយរបៀបណា? សូមគិតអំពីពាក្យប្រៀបធៀបអំពីពន្លឺម្តងទៀត។ ដូចជាយើងបានឃើញថា ព្រះវិញ្ញាណបរិសុទ្ធគឺដូចជាពន្លឺមួយបញ្ចាំងទៅក្នុងកន្លែងងងឹតរបស់យើង លាតត្រដាងអំពើបាបរបស់យើងហើយដឹកនាំយើងទៅឯការប្រែចិត្ត។ ព្រះវិញ្ញាណក៏ជាចង្កៀងមួយបំភ្លឺព្រះបន្ទូលព្រះ បង្រៀនអ្វីដែលជាសេចក្តីពិត និងបើកសំដែងឲ្យឃើញថាវាមានតំលៃ (១កូរិនថូស ២:៦-១៦) ហើយដូចជាយើងបានឃើញក្នុងយ៉ូហាន ជំពូក១៦ ដែលថា ព្រះវិញ្ញាណបញ្ចេញពន្លឺលើព្រះគ្រីស្ទដើម្បីឲ្យយើងអាចមើលឃើញសិរីល្អនិងសោភ័ណភាពរបស់ទ្រង់ ហើយយើងអាចបានផ្លាស់ប្រែ។

នៅក្នុង ២កូរិនថូស ៣:១៨ លោកប៉ុលសរសេរថា«ហើយយើងរាល់គ្នាទាំងអស់ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ទាំងមុខទទេដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់យើងកំពុងតែផ្លាស់ប្រែទៅឱ្យដូចជារូបឆ្លុះនោះឯងពីសិរីល្អទៅដល់សិរីល្អគឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ។»។

ដូចជាមុខរបស់លោកម៉ូសេត្រូវបានផ្លាស់ប្រែនៅពេលគាត់បានឃើញសិរីល្អរបស់ព្រះអម្ចាស់នៅលើភ្នំស៊ីណាយ នោះយើងនឹងបានផ្លាស់ប្រែផងដែរ នៅពេលយើងសំឡឹងមើលសិរីល្អរបស់ព្រះនៅលើព្រះភ័ក្ររបស់ព្រះគ្រីស្ទ។

យើងនឹងមិនគ្រាន់តែមានមុខភ្លឺ តែយើងនឹងរីកចំរើនកាន់តែខ្លាំងឡើងៗដូចជារូបអង្គដែលយើងមើលឃើញ។ យើងត្រឡប់ដូចជាអ្វីដែលយើងសំឡឹងមើល។

កីឡាករបាល់ទាត់អាជីពបង្ហាញជំនាញយ៉ាងអស្ចារ្យ។ ពួកគេភាគច្រើនរីកធំធាត់ជាមួយការមើលបាល់ទាត់។ នៅពេលពួកគេនៅក្មេង ពួកគេប្រហែលស្ងើចសរសើរដល់ជំនាញរបស់កីឡាការដែលពួកគេគោរពស្រលាញ់។ ពួកគេប្រហែលបានគិតថា “ខ្ញុំចង់ធ្វើដូចនោះដែរ។ វាអស្ចារ្យ! តើខ្ញុំអាចដូចជាពួកគេបានយ៉ាងម៉េច?” កីឡាករបាល់ទាត់កំរឹតពិភពលោកត្រូវការការអនុវត្ត ដូចជាយើងក៏ត្រូវមានការខិតខំប្រឹងប្រែងដើម្បីអោយយើងញែកជាបរិសុទ្ធផងដែរ។ ប៉ុន្តែការខិតខំក្នុងករណីទាំងពីរត្រូវបានជំរុញទឹកចិត្តដោយមើលឃើញគំរូល្អដែលមានភាពជោគជ័យ។ការមើលឃើញភាពភ្លឺចាំងនិងព្រះចេស្ដាបំផ្លាស់បំប្រែយើង។

ហេតុនេះវាគឺជាការអាក្រក់ដ៏ធំនៅពេលព្រះវិញ្ញាណកំពុងធ្វើការញែកយើងជាបរិសុទ្ធដោយការបើកសំដែងអំពើបាប ការបើកសំដែងសេចក្ដីពិតនិងការបើកសំដែងសិរីល្អរបស់ព្រះ ហើយយើងព្រងើយកន្តើយឬបដិសេធទ្រង់នោះ។ ព្រះគម្ពីរហៅការនេះថា ការទាស់ទទឹង (កិច្ចការ ៧:៥១) ការពន្លត់ (១ថែស្សាឡូនិច ៥:១៩) ឬការធ្វើឲ្យព្រះវិញ្ញាណបរិសុទ្ធព្រួយព្រះទ័យ (អេភេសូរ ៤:៣០)។ ពាក្យទាំងបីនេះអាចមានន័យខុសគ្នាបន្តិចបន្តួច ប៉ុន្តែពាក្យទាំងនេះនិយាយអំពីការដែលយើងមិនទទួលយកការងាររបស់ព្រះវិញ្ញាណនៅក្នុងជីវិតរបស់យើង។ នៅពេលយើងបដិសេធអ្វីដែលព្រះបន្ទូលព្រះនិយាយមកកាន់យើង នៅពេលយើងព្រងើយកន្តើយនឹងការ

លាតត្រដាងអំពើបាប នៅពេលយើងមិនប្រព្រឹត្តដូចជាគ្រីស្ទបរិស័ទទោះបើយើងប្រកាសថាយើងជាគ្រីស្ទបរិស័ទក៏ដោយ នោះយើងធ្វើបាបទាស់ប្រឆាំងនឹងព្រះវិញ្ញាណហើយ។[១៧]

## *ព្រះវិញ្ញាណបរិសុទ្ធប្រទានអ្វីៗដែលយើងត្រូវការដើម្បីយើងមានសមត្ថភាពបម្រើ*

ព្រះវិញ្ញាណបរិសុទ្ធមិនគ្រាន់តែប្រទានអំណាចឲ្យយើងរស់នៅដូចជាព្រះគ្រីស្ទនោះទេ តែទ្រង់ក៏ប្រទានអ្វីៗដែលយើងត្រូវការឲ្យយើងបម្រើដូចជាព្រះគ្រីស្ទផងដែរ។ “ភាពពេញលេញ” គឺជារបៀបមួយក្នុងការបរិយាយការប្រទានអំណោយទាននេះ។ព្រះវិញ្ញាណបំពេញយើងដោយភាពក្លាហាន ប្រាជ្ញា សេចក្ដីជំនឿ និងអំណរ (កិច្ចការ ៦:៣, ១១:២៤, ១៣:៥២)។ ថ្វីបើព្រះវិញ្ញាណគង់ក្នុងយើង តែទ្រង់នៅតែអាចបំពេញយើងឲ្យដល់កំរិតធំជាងឬតិចជាងបាន ដូចជាបាល់ធំអាចពេញដោយខ្យល់ ប៉ុន្តែបើសិនអ្នកផ្លុំខ្យល់ទៅក្នុងវា នោះវារីកប៉ោងហើយមានភាពពេញកាន់តែធំជាង។ ការពេញដោយព្រះវិញ្ញាណប្រហែលជានឹងនាំឲ្យអ្នកជាមនុស្សរំជួលតាមអារម្មណ៍។ ឬប្រហែលជានឹងនាំឲ្យអ្នកជាមនុស្សដែលឆាប់ឆ្លើយតប។ ប៉ុន្តែនៅពេលណាអ្នកថ្វាយបង្គំ សូមអរព្រះគុណ និងចុះចូលចំពោះព្រះ យើងធ្វើនោះដោយព្រោះព្រះវិញ្ញាណកំពុងបំពេញអ្នក (អេភេសូរ ៥:១៨-២១)។

**អំណោយទានខាងវិញ្ញាណ** “អំណោយទាន” គឺជារបៀបមួយទៀតក្នុងការនិយាយអំពីរបៀបព្រះវិញ្ញាណបរិសុទ្ធប្រទានអ្វីៗដែលយើងត្រូវការ។

ពាក្យ “អំណោយទាន” (charisma) គឺជាពាក្យដែលប្រើបានច្រើនយ៉ាង។[១៨] គិតឲ្យទូលំទូលាយគឺ អំណោយទានគឺជាការបើកសំដែងព្រះគុណរបស់ព្រះនៅក្នុងយើងនិងតាមរយៈរាស្ត្ររបស់ទ្រង់។[១៩] ១កូរិនថូស ១២:៤-៦ ប្រាប់ថាអំណោយទានស្មើនឹងការបម្រើឬសកម្មភាពមួយ។ បញ្ជីអំណោយទានធំៗនៅក្នុងព្រះគម្ពីរសញ្ញាថ្មីមិនមែនជាការពិពណ៌នាពេញលេញអំពីអំណោយទានរបស់ព្រះវិញ្ញាណនោះទេ (សូមមើលរ៉ូម ១២:៦-៨, ១កូរិនថូស ១២:៨-១០, ២៨ អេភេសូរ ៤:១១)។ បញ្ជីនានាខុសគ្នា។ ប៉ុលកំពុងនិយាយថា “ពួកជំនុំមានមនុស្សគ្រប់ប្រភេទ ទាំងអស់ដែលធ្វើការងារខុសៗគ្នាដោយព្រះហស្តរបស់ព្រះ។ ជាឧទាហរណ៍...” និយាយតាមរបៀបផ្សេង នៅទីណាព្រះគុណរបស់ព្រះបានបង្ហាញក្នុងរាស្ត្ររបស់ទ្រង់ នោះយើងមើលឃើញអំណោយទានរបស់ព្រះវិញ្ញាណកំពុងធ្វើការ។

គោលបំណងរបស់អំណោយទានរបស់ព្រះវិញ្ញាណមិនមែនសម្រាប់ឲ្យយើងអាចទាក់ទាញអ្នកដទៃឬផ្តល់បទពិសោធន៍អស្ចារ្យផ្ទាល់ខ្លួននោះទេ។ អំណោយទានរបស់ព្រះវិញ្ញាណគឺសម្រាប់សេចក្តីល្អរួមនិងការស្អាងចិត្តពួកជំនុំឡើង (១កូរិនថុស ១២:៧, ១៤:១២, ២៦)។ អំណោយទានគឺសម្រាប់ការបម្រើហើយផលប្រយោជន៍របស់រូបកាយព្រះគ្រីស្ទ។

លើសពីនេះ ព្រះវិញ្ញាណបរិសុទ្ធប្រទានអំណោយទានដល់ពួកគ្រីស្ទបរិស័ទតាមដែលទ្រង់ចង់ (១២:១១)។ ព្រះវិញ្ញាណបរិសុទ្ធមិនប្រទានអំណោយទានដល់រាស្ត្ររបស់ព្រះដោយចៃដន្យនោះទេ។ ទេ ព្រះវិញ្ញាណបរិសុទ្ធបានចែកអំណោយទានដោយប្រយ័ត្នប្រយែង។ ព្រះវិញ្ញាណប្រទានអោយគ្រីស្ទបរិស័ទ

ម្នាក់ៗមានអំណោយ ប្រយោជន៍ដើម្បីអោយគេបម្រើព្រះអង្គនិងមនុស្ស។ នេះមានន័យថា យើងមានសមត្ថភាពក្នុងការបម្រើ។ វាក៏មានន័យថា យើងត្រូវតែបម្រើ។មិនខ្វល់ថានៅខាងក្នុងឬខាងក្រៅអាគារព្រះវិហារនោះទេ យើងម្នាក់ៗត្រូវតែធ្វើការសម្រាប់សេចក្តីល្អរួម។ ពួកជំនុំមិនដូចជាការទៅមើលកុននោះទេ។ វាដូចជាទាហ៊ានម្នាក់នៅក្នុងជួរកងទ័ពអញ្ចឹង។ ទាហ៊ានម្នាក់ៗត្រូវតែបំពេញកិច្ចការរបស់ខ្លួន គឺយើងមិនត្រូវគិតតែពីអង្គុយនិងសំរាកនៅពេលយើងទៅពួកជំនុំនោះឡើយ។

**អំណោយទានដែលគ្រីស្ទបរិស័ទមានទស្សនៈខុសគ្នា** ខ្ញុំនឹងធ្វេសប្រហែសក្នុងការនិយាយអំពីអំណោយទានខាងឯវិញ្ញាណបើសិនជាខ្ញុំមិនបាននិយាយអ្វីអំពីការពិភាក្សាលើ “អំណោយទានដ៏អស្ចារ្យ”។ ទស្សនៈមួយ (ដែលយើងហៅថា ពួកអ្នកឈប់ផ្អាក cessationists) បង្រៀនថា អំណោយទានខ្លះដូចជាការនិយាយភាសាដទៃនិងទំនាយ បានបញ្ឈប់(លែងមាន)បន្ទាប់ពីសម័យពួកសាវ័ក។ ពួកគេជឿថា:

១. អំណោយទានអស្ចារ្យចាំបាច់សម្រាប់តែទីសំគាល់ពិតប្រាកដសម្រាប់ដំណឹងល្អនិងការបង្កើតពួកជំនុំដំបូងប៉ុណ្ណោះ។

២. ១កូរិនថូស ១៣:៨-១០ និយាយថា ទំនាយ ភាសាដទៃ និងចំណេះដឹងនឹងបាត់ទៅ “នៅពេលសេចក្តីគ្រប់លក្ខណ៍បានមកដល់”។ ពួកអ្នកឈប់ផ្អាកភាគតិចជឿថា “សេចក្តីគ្រប់លក្ខណ៍” បានមកដល់ជាមួយនឹងការសរសេរព្រះគម្ពីរត្រូវបាន

បញ្ចប់។

៣. អំណោយទានបើកសំដែងដូចជាការនិយាយភាសាដទៃនិងទំនាយ បំផ្លាញអំណាចនិងភាពគ្រប់គ្រាន់របស់ព្រះគម្ពីរ។

៤. អំណោយទានអស្ចារ្យដែលយើងឃើញសព្វថ្ងៃនេះមិនមែនដូចជាអំណោយទានដែលត្រូវបានប្រើនៅក្នុងគម្ពីរសញ្ញាថ្មីនោះទេ។

ម៉្យាងវិញទៀត ពួកអ្នកបន្ត continuationists បង្រៀនថា គ្រប់អំណោយទានទាំងអស់មាននៅសព្វថ្ងៃនេះ។ ពួកគេជឿថាៈ

១. ដោយគ្មានពាក្យផ្ទុយច្បាស់លាស់ចំពោះអំណោយទានទាំងនោះ នោះយើងគួរតែសន្មត់ថា គ្រប់អំណោយទាំងអស់នៅតែមានសព្វថ្ងៃ ហើយយើងគួរតែចង់បានពួកវា (១កូរិនថូស ១៤:១)។

២. “សេចក្តីគ្រប់លក្ខណ៍” នៅក្នុង១កូរិនថូស ជំពូក១៣ សំដៅលើការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទ មិនមែនលើការបញ្ចប់ព្រះគម្ពីរសាសនបញ្ញត្តិនោះទេ (ហើយ ពួកអ្នកឈប់ផ្អាក cessationists ច្រើនក៏ទទួលយកចំនុចនេះផងដែរ ប៉ុន្តែពួកគេមានការសន្និដ្ឋានខុសគ្នា)។

៣. អំណោយទានបើកសំដែងមិនមានអំណាចស្មើនឹងព្រះគម្ពីរនោះទេ។ យើងត្រូវតែសាកល្បងអំណោយទានទាំងនោះ។

៤. ថ្វីបើអំណោយទានសព្វថ្ងៃពិតជាដូចគ្នានឹងសតវត្សទីមួយឬអត់ យើងគួរតែស្វាគមន៍ការងាររបស់ព្រះវិញ្ញាណនៅក្នុងកណ្តាលចំណោមយើង។

ខ្ញុំជឿថា ភាគីទាំងពីរមើលឃើញថា ពួកគេឥឡូវនេះយល់ស្របជាមួយគ្នាច្រើនជាងពួកគេធ្លាប់បានគិត។ ពួកគេយល់ស្របថា:

១. យើងត្រូវតែសាកល្បងគ្រប់ការប្រកាសទាំងអស់ជាមួយនឹងព្រះគម្ពីរ។

២. យើងមិនអាចបន្ថែមអ្វីចូលក្នុងព្រះគម្ពីរឡើយ។

៣.វាមិនមែនជាប្រាជ្ញានោះទេក្នុងការអះអាងថា អ្នកបានទទួលព្រះបន្ទូលផ្ទាល់ពីព្រះអម្ចាស់សម្រាប់អ្នកផ្សេងទៀត។

៤. យើងគួរតែបើកចំហជាមួយការងាររបស់ព្រះវិញ្ញាណ មិនខ្វល់ថា វាហៅថា “ទំនាយ” “ការបំភ្លឺ” ឬ អ្វីផ្សេងទៀតនោះឡើយ។

ការដែលលើកទឹកចិត្តមួយនៅក្នុងក្រុមជំណឹងល្អនិយមគឺ របៀបដែលពួកអ្នកឈប់ផ្អាកនិងពួកអ្នកបន្តអាចចាប់ដៃគូជាមួយគ្នានិងថ្វាយបង្គំជាមួយគ្នាក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ដោយដឹងថាភាពរួមរបស់ពួកគេនៅក្នុងដំណឹងល្អគឺមានសារៈសំខាន់ខ្លាំងជាងបញ្ហាទាក់ទងនឹងអំណោយទានខាងឯវិញ្ញាណដែលធ្វើឲ្យពួកគេបាក់បែកគ្នា។

## *ព្រះវិញ្ញាណបរិសុទ្ធសន្យា*

នៅក្នុងអេភេសូរ ១:៣ លោកប៉ុលបានចាប់ផ្តើមការសរសើរតម្កើងព្រះសម្រាប់ព្រះពរដែលជារបស់យើងនៅក្នុងព្រះគ្រីស្ទយេស៊ូវ។ បញ្ជីព្រះពរបានឈានដល់ចំនុចខ្ពស់មួយដែលមានការដៅចំណាំដោយព្រះវិញ្ញាណៈ

«ឯអ្នករាល់គ្នាក៏បានឮព្រះបន្ទូលនៃសេចក្តីពិត គឺជាដំណឹងល្អពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ ហើយកាលអ្នករាល់គ្នាបានជឿ ហើយនោះទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធដែលបានសន្យាព្រះវិញ្ញាណនោះទ្រង់ជាទីបញ្ចាំចិត្តពីដំណើរកេរ្តិ៍អាកររបស់យើងរាល់គ្នាទាល់តែបានលោះរបស់កំណាន់ ដែលទ្រង់បានទិញទុកឱ្យយើងនោះ សម្រាប់ជាសេចក្តីសរសើរដល់សិរីល្អនៃទ្រង់។» (អេភេសូរ១:១៣-១៤)។

**ការដៅចំណាំ។** តើការបានដៅចំណាំដោយព្រះ វិញ្ញាណបរិសុទ្ធដែលបានសន្យាមានន័យយ៉ាងដូចម្តេច? ពាក្យនេះហាក់ដូចជាមិនច្បាស់លាស់ចំពោះយើង ប៉ុន្តែប្រហែលជាពួកក្រុងអេភេសូរមិនដូច្នេះទេ។ ការដៅចំណាំក្នុងសម័យកាលបុរាណបានធ្វើការបីយ៉ាង។ ១. ការដៅចំណាំផ្តល់ភស្តុតាងថា«នេះមិនក្លែងក្លាយទេ» សូមគិតអំពីសំបុត្រមួយដែលមានតែមផ្លូវការរបស់ស្តេចបិទដោយការ។ ២. ការដៅចំណាំដូចជាដែកបោះ ត្រាលើសត្វដើម្បីកុំឲ្យមានចោរលួចបាន។៣. ការដៅចំណាំសំគាល់ថាមានម្ចាស់។ លោកប៉ុលប្រើរូបភាពដៅចំណាំនេះក្នុងការពិពណ៌នាគំនិតដូចគ្នា។

ការដៅចំណាំដោយព្រះវិញ្ញាណបង្ហាញថា យើងពិតជាគ្រីស្ទបរិស័ទពិតប្រាកដ ធ្វើឲ្យយើងមានសុវត្ថិភាពអស់កល្បជានិច្ច និងដៅចំណាំយើងជា

កម្មសិទ្ធរបស់ព្រះ។ វាដូចជាព្រះបានបិទតែមលើយើងជារបស់ទ្រង់ផ្ទាល់។ ទោះបើមានគ្រីស្ទបរិស័ទខ្លះមិនយល់ស្របក៏ដោយ ក៏ខ្ញុំជឿថា ការដៅចំណាំដោយព្រះវិញ្ញាណកើតមាននៅពេលយើងប្រែចិត្តជឿលើព្រះ យេស៊ូវ។ លោកពេត្រុស អូប្រៀន Peter O'Brien និយាយថា «ការដៅចំណាំគឺជាលើកឡើងអំពីការដែលពួកអ្នកអានបានទទួលព្រះវិញ្ញាណ។ លោកប៉ុលភ្ជាប់ការឮដំណឹងល្អ ការជឿ និងការទទួលព្រះវិញ្ញាណជាមួយគ្នា ហើយទាំងនេះគឺជាធាតុសំខាន់នៅពេលចាប់ផ្តើមប្រែចិត្តជឿ»។[២០]

សេចក្តីជំនឿនិងការដៅចំណាំបានកើតមានក្នុងពេលតែមួយ ដូច្នេះលោកប៉ុលអាចសរសេរទៅកាន់ពួកក្រុងអេភេសូរពីចំងាយ ហើយបានធានាថា ពួកគេទាំងអស់គ្នាត្រូវបានដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធដែលបានសន្យា។ ការដៅចំណាំគឺជាការងារដែលព្រះធ្វើក្នុងយើងក្នុងពេលតែមួយជាមួយការកែជាថ្មីឡើងវិញនិងការគង់នៅក្នុងជីវិតយើងដោយព្រះវិញ្ញាណបរិសុទ្ធ។ ការដៅចំណាំគឺពិតប្រាកដហើយវាមិនផ្អែកលើអារម្មណ៍របស់យើងឡើយ។

ប៉ុន្តែទោះបីជាការងារនេះមិនផ្អែកលើអារម្មណ៍របស់យើងក៏ដោយ នោះមិនមានន័យថាយើងមិនអាចមានបទពិសោធន៍ពីព្រះវិញ្ញាណនោះទេ។ យើងគួរតែអធិស្ឋានដើម្បីទទួលបានសេចក្តីស្រលាញ់របស់ព្រះដែលបានចាក់បង្ហូរមកក្នុងចិត្តរបស់យើង (រ៉ូម ៥:៥)។ យើងមិនគ្រាន់តែគួរសង្ឃឹមចង់ស្គាល់ព្រះវិញ្ញាណជាការធានារបស់យើងប៉ុណ្ណោះទេ ប៉ុន្តែយល់ជ្រៅនៅក្នុងចិត្តថាទ្រង់ដៅចំណាំយើងទុកសម្រាប់មរតករបស់យើង (២កូរិនថូស ៥:៥ អេភេសូរ ៤:៣០)។ ទោះជានៅពេលយើងមិនមានអារម្មណ៍ថាយើងមានការធានា

ទាំងស្រុងក៏ដោយ ក៏ការដៅចំណាំដោយព្រះវិញ្ញាណនៅជាមួយយើងដែរ ដូចជាកៅអីរឹងមាំមួយទ្រយើងឡើងបើទោះជាយើងភ័យខ្លាចថាវាគ្រាន់តែជាកៅអីមិនរឹងមាំក៏ដោយ។ ទោះយ៉ាងណា វាប្រសើរជាងដែលអង្គុយយ៉ាងសុខស្រួលលើកៅអីដោយដឹងសេចក្តីពិតថាវារឹងមាំ ហើយធានាថាយើងមិនមានគ្រោះថ្នាក់។

ការដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធដែលបានសន្យាធ្វើឲ្យយើងមានសុវត្ថិភាពនៅថ្ងៃនៃសេចក្តីប្រោសលោះ(ថ្ងៃចុងក្រោយ) ជាអំណោយទានដែលគ្រីស្ទបរិស័ទគ្រប់រូបទទួលបាន ហើយគ្រីស្ទបរិស័ទគ្រប់រូបត្រូវរីករាយជាមួយវា (អេភេសូរ ១:១៨)។ ព្រះប្រទានព្រះវិញ្ញាណមកយើងហើយនិងនិយាយមកកាន់យើងថា «សេចក្តីសន្យានេះគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ។ ឯងមិនអាចស្រមើស្រម៉ៃថាខ្ញុំនឹងប្រទានពរដល់ឯងប៉ុណ្ណានោះទេ។ មានវិវាហៈមង្គលបានរៀបចំសម្រាប់ឯងដែលធំលើសការស្រមើស្រម៉ៃរបស់ឯង។ ប៉ុន្តែខ្ញុំបានប្រទានព្រះវិញ្ញាណរបស់ខ្ញុំដល់ឯងដើម្បីឲ្យឯងនឹងជឿថា ពិធីនោះនឹងមកដល់»។

**ចូរដើរទៅមុខហើយគោះចុះ។** តើយើងគួរតែអនុវត្តសេចក្តីពិតទាំងនេះអំពីព្រះវិញ្ញាណបរិសុទ្ធនិងការងាររបស់ទ្រង់? ព្រះយេស៊ូវមានការទូន្មានល្អខ្លះ។ ប៉ុន្តែដំបូងខ្ញុំសូមនិយាយរឿងមួយ។

នៅព្រឹកថ្ងៃសៅរ៍ម៉ោងប្រាំពីរ ដែលមានន័យថា បើសិនវាជារដូវរងារហើយអ្នករស់នៅកន្លែងដែលខ្ញុំរស់នៅ នោះព្រះអាទិត្យមិនទាន់រះនៅម៉ោងនេះទេ។ បើទោះវានៅងងឹត អ្នករៀបចំអាហារពេលព្រឹកដោយព្រោះអ្នកឃ្លាន។ អ្នកត្រូវ

ការស៊ុតប៉ុន្តែអ្នកអត់មានស៊ុតមួយណាទេ។ គ្រាន់តែស៊ុតមួយគឺជាអ្វីដែលអ្នក និងគ្រួសាររបស់អ្នកចង់បរិភោគ។ អ្នកដើរទៅកាន់ផ្ទះរបស់អ្នកជិតខាងរបស់អ្នកហើយគោះទ្វារដោយប្រយ័ត្នប្រយែង។ បន្ទាប់ពីស្ងាត់បានមួយនាទី ទ្វារក៏បើកបន្តិច។

“តើអ្នកត្រូវការអ្វី? វាជាពេលព្រឹកថ្ងៃសៅរ៍។ ក្មេងៗទាំងអស់កំពុងគេងនៅឡើយ។ ខ្ញុំក៏គួរតែកំពុងគេងដែរ”។ អ្នកឆ្លើយថា “ឲ្យខ្ញុំសូមទោសដែលរំខានអ្នក គឺខ្ញុំគ្រាន់តែត្រូវការស៊ុតមួយប៉ុណ្ណោះ”។ ពួកគេឆ្លើយថា “សូមត្រឡប់មកវិញនៅម៉ោងប្រាំបួនកន្លះ”។ ប៉ុន្តែអ្នកដាក់ជើងទៅក្នុងទ្វារហើយសុំម្តងទៀត។ “សូមឲ្យខ្ញុំផង ខ្ញុំអាចមើលឃើញស៊ុតរបស់អ្នកពីទីនេះ។ អ្នកនឹងមិនចំណាយពេលលើសជាងដប់វិនាទីដើម្បីយកវាមកឲ្យខ្ញុំនោះទេ។ គ្រាន់តែស៊ុតមួយប៉ុណ្ណោះ។ បន្ទាប់មកអ្នកអាចត្រឡប់ទៅគេងវិញបាន”ហើយដោយសារតែភាពមានះរបស់អ្នក នោះអ្នកទទួលបានស៊ុតមួយ ហើយគ្រួសាររបស់អ្នកបានបរិភោគអាហារពេលព្រឹក។

ព្រះយេស៊ូវបានប្រាប់រឿងមួយដូចនេះម្តង។ ទ្រង់បានមានបន្ទូលថា

> បានជាខ្ញុំប្រាប់អ្នករាល់គ្នាថាចូរសូមនោះតែងនឹងអោយមកអ្នក
> ចូររកនោះតែងនឹងឃើញចូរគោះនោះតែងនឹងបើកអោយអ្នកដ្បិត
> អស់អ្នកដែលសូមនោះរមែងបានអ្នកណាដែលរកនោះរមែង
> ឃើញក៏បើកអោយអ្នកណាដែលគោះដែរ។ឯអ្នករាល់គ្នាដែលជា
> ឪពុកបើកូនសូមនំប៉័ងតើអ្នកណានឹងអោយថ្មទៅវាឬបើសូមត្រីតើ
> នឹងអោយពស់វិញឬ?បើវាសូមពងមាន់តើនឹងអោយខ្យាដំរីឬអី?បើ

> អ្នករាល់គ្នាដែលជាមនុស្សអាក្រក់អ្នកចេះអោយរបស់ល្អទៅកូន
> យ៉ាងដូចច្នេះនោះចំណង់បើព្រះវរបិតាដែលគង់ស្ថានសួគ៌តើ
> ទ្រង់នឹងប្រទានព្រះវិញ្ញាណបរិសុទ្ធមកអស់អ្នកដែលសូមជាជាង
> អម្បាលម៉ានទៅទៀត។ (លូកា ១១:៩-១៣)

ព្រះវរបិតានៃស្ថានសួគ៌របស់អ្នកស្រលាញ់អ្នកខ្លាំងជាងអ្នកស្រលាញ់គ្រួសាររបស់អ្នកទៅទៀត។ យើងមិនដែលបានឲ្យពស់ជាអំណោយដល់កូនរបស់យើងទេ ព្រោះបើទោះយើងអាក្រក់ ក៏យើងចង់ឲ្យអំណោយល្អៗដល់កូនៗនិងចៅៗរបស់យើងដែរ។ ដូច្នេះ តើលើសជាងប៉ុណ្ណាទៅទៀតដែលព្រះសព្វព្រះទ័យប្រទានអំណោយល្អៗដល់យើងនោះ?

ដូច្នេះ ចូរដើរទៅមុខហើយគោះចុះ។ សុំទ្រង់នូវអំណោយល្អបំផុត។ សុំទ្រង់នូវវត្តមានរបស់ព្រះវិញ្ញាណកាន់តែច្រើននៅក្នុងជីវិតរបស់អ្នក។ សុំព្រះ ឲ្យបំពេញពួកជំនុំរបស់អ្នកដោយអំណាចរបស់ព្រះវិញ្ញាណ។ តើអ្នកមិនចង់កាន់តែដូចជាព្រះគ្រីស្ទ មានការប្រែចិត្តជឿកាន់តែខ្លាំង មានការគោរពព្រះអម្ចាស់កាន់តែខ្លាំងឬ? តើអ្នកមិនចង់ឲ្យពួកជំនុំរបស់អ្នកកាន់តែមានសេចក្ដីស្រលាញ់កាន់តែស្មោះត្រង់ កាន់តែក្លាហាន កាន់តែថ្វាយសិរីល្អដល់ព្រះឬ? តើអ្នកមិនចង់បានភាពពេញលេញដោយព្រះវិញ្ញាណកាន់តែធំឬ? អ្វីទាំងអស់ដែលយើងត្រូវតែធ្វើគឺសុំ។ សុំព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកនឹងទទួលបានទ្រង់ ចូររកនោះអ្នកតែងនឹងឃើញ ចូរគោះ នោះតែងនឹងបើកឲ្យអ្នក។

# កំណត់

១. Sinclair B. Ferguson, The Holy Spirit (Downers Grove, IL: InterVarsity, 1996), 21.

២. This list is culled from Robert Letham, The Holy Trinity: In Scripture, History, Theology, and Worship (Phillipsburg, NJ: P&R, 2004), 60–61.

៣. ខគម្ពីរយោងដែលត្រូវបានដកស្រង់ចេញពីព្រះគម្ពីរខ្មែរបរិសុទ្ធ (១៩៥៤).

៤. Ferguson, Holy Spirit, 37.

៥. ព្រះគម្ពីរបង្រៀនយ៉ាងច្បាស់ថា ព្រះវិញ្ញាណត្រូវបានព្រះវរបិតា និងព្រះរាជបុត្រាបញ្ជូនមក នោះវាមិនសូវច្បាស់លាស់ទេថា ព្រះវិញ្ញាណបណ្ដាលមកពីព្រះវរបិតានិងព្រះរាជបុត្រាអស់កល្បជានិច្ច។ យោងតាមគោលជំនឿរបស់ណាយសៀនិងខុនស្តាន់ទីណូផល Niceno-Constantinoplitan Creed (៣៨៩គ.ស) ព្រះវិញ្ញាណបរិសុទ្ធ “បណ្ដាលមកពីព្រះវរបិតា”។ ឃ្លា “និងព្រះរាជបុត្រា” (filioque) ត្រូវបានបន្ថែមនៅឯក្រុមប្រឹក្សារបស់ Toledo ក្នុងឆ្នាំ៥៨៩គ.ស ដែលនាំទៅដល់ការបែកបាក់មតិគ្នារវាងពួកជំនុំខាងកើតនិងពួកជំនុំខាងលិច។ ជំលោះដែលកើតមានតាមក្រោយនោះគឺទាក់ទងនឹងនយោបាយខ្លះ ទេវសាស្ត្រខ្លះ និងការយល់ច្រឡំខ្លះ។ សេចក្ដីបង្រៀនរបស់ពួកជំនុំខាងលិចស៊ីគ្នាបានល្អជាមួយនិងការផ្ដោតលើការងាររបស់

ព្រះវិញ្ញាណក្នុងការបង្កើតយើងឡើងវិញនៅក្នុងរូបភាពនៃព្រះគ្រីស្ទ ហើយការពារប្រឆាំងនឹងទស្សនៈអំពីសេចក្តីសង្គ្រោះដែលដាក់ការងាររបស់ព្រះវិញ្ញាណនៅកណ្តាលហើយដាច់ចេញពីព្រះគ្រីស្ទ។ ប៉ុន្តែអស់អ្នកដែលជឿ filioque (ដូចជាខ្ញុំជឿ) ត្រូវតែស្តាប់ទស្សនៈរបស់និកាយអូតូដុកខាងកើតដោយប្រយ័ត្នប្រយែង។

៦. See D. A. Carson, The Gospel according to John (Grand Rapids, MI: Eerdmans, 1991), 534–39.

៧. Jonathan Edwards, “The Distinguishing Marks of a Work of the Spirit of God,” in Jon¬athan Edwards on Revival (1741; repr., Edinburgh: Banner of Truth, 1995), 121.

៨. See John Piper, Finally Alive (Ross-shire, Scotland: Christian Focus, 2009), 30–31.

៩. Ibid., 39–42.

១០. John Calvin, Institutes of the Christian Religion, ed. John T. McNeil; trans. Ford Lewis Battles (Philadelphia: Westminster, 1960), 3.1.1.

១១. Ibid.

១២. John Murray, Redemption, Accomplished and Applied (Grand Rapids, MI: Eerdmans, 1955), 161.

១៣. According to Ferguson, Holy Spirit, 100.

១៤. John Stott, Baptism and Fullness: The Work of the Holy Spirit

Today (Downers Grove, IL: InterVarsity, 1975), 43.

១៥. J. I. Packer, Keep in Step with the Spirit: Finding Fullness in Our Walk with God (Grand Rapids, MI: Baker, 2005), 57.

១៦. C. S. Lewis, Mere Christianity (1943; repr., New York: Touchstone, 1996), 178.

១៧. See Graham Cole, Engaging with the Holy Spirit: Real Questions, Practical Answers (Wheaton, IL: Crossway, 2007), 49, 81, 97.

១៨. See Rom. 1:11; 5:15–16; 6:23; 11:29; 2 Cor. 1:11; Heb. 2:4.

១៩. On this point, charismatics and noncharismatics are in agreement. See Wayne Gru¬dem, Systematic Theology: An Introduction to Biblical Doctrine (Grand Rapids, MI: Zondervan, 1994), 1016; Richard B. Gaffin, Perspectives on Pentecost: New Testament Teaching on the Gifts of the Holy Spirit (Phillipsburg, NJ: P&R, 1979), 47.

២០. Peter T. O'Brien, The Letter to the Ephesians (Grand Rapids, MI: Eerdmans, 1999), 120.